ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ១ ត្រីមាសទី១ ឆ្នាំ២០២០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក
ស
វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតរដ្ឋបុរសជាតិ

**ការពង្រីកវប្បធម៌សន្តិភាព និងការប្រយុទ្ធដើម្បីអភិវឌ្ឍ
គឺជាសង្គ្រាមរបស់ខ្ញុំនិងរបស់យើងទាំងអស់គ្នា
នាដើមសហស្សវត្សរ៍ថ្មីនេះ។**

កម្ពុជាឆ្នាំ២០០០ - សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង
- យឹម ណុលសន

និពន្ធនាយក
- អ៊ីវ ចុង

និពន្ធនាយករង
- អ៊ុន វ៉ាល់ឡឺរ៉ូ
- ប៉ិច សុខា

ការិយាល័យនិពន្ធ
- នរ៉ាណាឫទ្ធិ អាននន្ទដាយ៉ាត
- លី គឹមសុខ
- ឆយ អុន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អ្នកចាត់ចែងផលិត
- អ៊ុន វ៉ាល់ឡឺរ៉ូ
- រ័ត្ន សណ្តាប់

អ្នកចែកផ្សាយ
- អេង រត្នមុនី
- សំ សំណាង
- សេក វុទ្ធី

ការីកុំព្យូទ័រ
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- វិចារណកថា " អរគុណសន្តិភាព " ១-២

II- បទអត្ថាធិប្បាយ " អរិយធម៌ខ្មែរសម័យអង្គរ " ៣-៨

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩-២០២៣ ៩-១០

២- សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ ១១

៣- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ ១២-១៣

IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១៩ ១៤-២០

V- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ២១-២៦

VI- នាទីវប្បធម៌

- ពន្យល់ពាក្យ " ទោស " ២៧
- យល់ដឹងអំពីបុណ្យចូលឆ្នាំថ្មី ២៨-៣៣

VII- នាទីកំណាព្យ

- រៀនអំណត់ ( បទរលកខ្ទប់ច្រាំង - ពាក្យ៩ ) ៣៤
- ចំពោះនារី( បទពាក្យ៧ ) ៣៤
- ក្រមុំតូច ( បទពាក្យ៩ ) ៣៤

VIII- នាទីកំសាន្ត

- ដើរខ្យល់ ៣៥
- ស្នូមចម្លែក ៣៥

IX- វដ្តជីវិតនៃត្រីប៉ាសេអ៊ី និងសមត្ថភាពធម្មជាតិនៃការសម្របសម្រួលទម្លាប់រស់នៅ បន្តរពូជពង្សរបស់វា ទៅតាមការប្រែប្រួលនៃបរិស្ថានធម្មជាតិ ៣៦-៤៣

# អរគុណសន្តិភាព

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ឈុលឡា*

មានហេតុផលមួយចំនួនដែលត្រូវនិយាយអំពីសន្តិភាពសព្វថ្ងៃនេះនៅកម្ពុជាព្រោះវាពុំមែនជាអ្វីរកបានដោយងាយ ហើយក៏ពុំមែនជាអ្វីដែលមានន័យស្រាលៗដូចអ្នកខ្លះយល់នោះទេ។ ប្រជាជនកម្ពុជាទូទៅដែលកំពុងរស់នៅក្នុងប្រទេស ហើយធ្លាប់ហែលឆ្លងកាត់សង្គ្រាមឆាបឆេះពេញផ្ទៃប្រទេសឆ្នាំ១៩៧០-១៩៧៥ រវាងកងទ័ពសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ គាំទ្រដោយអាមេរិក និងកងទ័ពរំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា ជាពិសេសទៅទៀតគឺអ្នកសល់ពីស្លាប់កាលពីសម័យអន្ធការក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ឆ្នាំ១៩៧៥-១៩៧៩សុទ្ធតែយល់ច្បាស់គ្មានស្រពិចស្រពិលទេអំពីអ្វីជាសន្តិភាព។សម័យប៉ុលពតគ្មានសង្គ្រាមមែនពិត តែប្រជាជនត្រូវគេបំបិទសិទ្ធិសេរីភាពដើរហើរ និយាយស្តី មិនឲ្យរស់នៅជួបជុំគ្រួសារ កុមារគ្មានសិទ្ធិរៀនសូត្រ...ហើយត្រូវរងពលកម្មធ្ងន់ធ្ងរនិងការកាប់សម្លាប់អស់ជិត២លាននាក់។ស្ថានភាពដូចនេះយើងទទួលបានឬទេ?

ផ្លូវទៅរកសន្តិភាពមួយថ្មីដែលឈានមកដល់ពេលនេះ វាបានចាប់កំណើតដំបូងពីថ្ងៃ៧ មករា ១៩៧៩ ជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជាដែលបានធ្វើការតស៊ូដោយមានការគាំទ្រពីកងទ័ពស្ម័គ្រចិត្តវៀតណាម ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយបើកសករាជថ្មី នាំមកនូវជីវិតថ្មី ជាជីវិតទី២និងសិទ្ធិសេរីភាពជូនប្រជាជន។ក្នុងដំណាក់កាលប្រវត្តិសាស្ត្រគ្មានស្ថិរភាពប្រមាណ១០ឆ្នាំក្រោយពីនេះ សន្តិភាពត្រូវស្ថិតនៅក្នុងសង្គ្រាមតស៊ូប្រទាញប្រទង់រវាងកម្លាំងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាទើបបង្កើតថ្មី និងកម្លាំងរបស់រដ្ឋាភិបាលចម្រុះត្រីភាគីដែលធ្វើការតស៊ូនៅតំបន់ជាយដែន ដើម្បីផ្តួលរលំរបបថ្មីនៅកម្ពុជា រហូតដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីបញ្ហាកម្ពុជា ថ្ងៃ២៣ តុលា ១៩៩១ ដែលនាំទៅដល់ការបោះឆ្នោតសាកលឆ្នាំ១៩៩៣ ដើម្បីសន្តិភាពនៅកម្ពុជា។

បន្ទាប់ពីការបោះឆ្នោតនេះ សន្តិភាពដែលរៀបចំដោយអង្គការសហប្រជាជាតិត្រូវស្ថិតក្នុងសង្គ្រាមបន្តទៀត ព្រោះភាគីខ្មែរក្រហមដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ ស្តីពីបញ្ហាកម្ពុជាមិនចូលរួមបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអ៊ុនតាក់(UNTAC)ទេ តែបែរជាបន្តសកម្មភាពនយោបាយ និងយោធារបស់ខ្លួននៅតំបន់ពាយ័ព្យនិងខាងជើងប្រទេសទៅវិញ។ ស្ថានភាពអាក្រក់នេះត្រូវបញ្ចប់ទាំងស្រុងដោយសារ**នយោបាយឈ្នះឈ្នះ** របស់**សម្តេចតេជោ ហ៊ុន សែន** នៅខែធ្នូ ឆ្នាំ១៩៩៨ ដែលនាំឲ្យអង្គការចាត់តាំងទាំងនយោបាយ ទាំងយោធារបស់ខ្មែរក្រហមត្រូវបានរំសាយនៅនឹងកន្លែងហើយមកចូលរួមកសាងប្រទេសជាមួយរាជរដ្ឋាភិបាលកម្ពុជាបង្កើតបាននូវសន្តិភាពស្ថាពរនិងពេញលេញជូនប្រជាជនកម្ពុជា គឺជា "**សន្តិភាព ភ្លឺស្រឡះ**" ដែលបើកទូលាយនូវសិទ្ធិសេរីភាពនិងប្រជាធិបតេយ្យជូនប្រជាជន និងផ្តល់ឱកាសឲ្យមានការអភិវឌ្ឍគ្រប់វិស័យនៅទូទាំងប្រទេសតាមពាក្យស្លោក"**មានសន្តិភាព មានការអភិវឌ្ឍ**"។

ពាក្យស្លោក"**អរគុណសន្តិភាព**" ក្នុងសារនយោបាយជាប្រវត្តិសាស្ត្ររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ថ្លែងក្នុងឱកាសខួបទី៤១ នៃទិវាជ័យជម្នះ ៧ មករា ២០២០ យើងជាប្រជាជនមើលឃើញអត្ថន័យដ៏មានតម្លៃជាសច្ចធម៌ ព្រោះថា **បើគ្មានសន្តិភាព ក៏គ្មានថ្ងៃនេះទេ** ទាំងគ្រួសារយើងម្នាក់ៗ ទាំងសង្គមជាតិទាំងមូល។ **អរគុណសន្តិភាព**ព្រោះសន្តិភាពបានផ្តល់ឱកាសចម្បង៣ដល់យើង គឺ១-គ្រួសារនីមួយៗអាចរស់នៅដោយសុខសាន្តជួបជុំគ្នាកូនចៅបានរៀនសូត្រមិនដូចសម័យសង្គ្រាមដែលត្រូវរត់លូនគេចពីគ្រាប់កាំភ្លើងគ្រាប់ផ្លោង ឬត្រូវបំបែកសមាជិកទៅធ្វើការកន្លែងផ្សេងៗគ្នា ក្រោមការបញ្ជាដាច់ខាតរបស់អង្គការក្នុងរបបប៉ុល ពត ២-គ្រួសារនីមួយៗអាចប្រកបរបរចិញ្ចឹមជីវិតដោយសេរីទៅតាមសមត្ថភាព និងការជ្រើសរើសរបស់សមាជិកម្នាក់ៗ ទាំងការងាររដ្ឋ ទាំងការងារឯកជន ដែលនាំឲ្យជីវភាពគ្រួសារមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃហើយសង្គមជាតិយើងទាំងមូលមានការអភិវឌ្ឍដូចសព្វថ្ងៃនេះនិង៣-ក្រៅពីមូលដ្ឋានដែលយើងកំពុងរស់នៅរាល់ថ្ងៃ យើងអាចធ្វើដំណើរទៅរកស៊ី ធ្វើការ កម្សាន្តដោយសុវត្ថិភាពពេញផ្ទៃប្រទេសទៅទីជិតឆ្ងាយទោះពេលថ្ងៃឬយប់ នៅលើផ្លូវធំល្អ និងឆ្លងកាត់ស្ពានទំនើបៗ ពីទីក្រុងរហូតដល់ជនបទដាច់ស្រយាល។

ក្រោមដំបូលស**ន្តិភាព**តែមួយនេះ កម្ពុជាមាន**ការអភិវឌ្ឍដ៏ឆាប់រហ័ស** ប្រជាជនយើងមានជីវភាពកើនឡើងជាលំដាប់ ជាពិសេសស្ថិរភាពនយោបាយបានផ្តល់ទំនុកចិត្តដល់វិនិយោគិនទាំងក្នុងប្រទេស ទាំងក្រៅប្រទេសដែលបង្កលក្ខណៈឲ្យកម្ពុជាទទួលបានអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧%ក្នុងរយៈពេល២ទសវត្សនេះនាំឲ្យកម្ពុជាឈានដល់ស្ថានភាពជាប្រទេសមានចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន ហើយអត្រាភាពក្រីក្រក៏បានថយចុះជាលំដាប់មកនៅត្រឹមអត្រាទាបជាង១០%។ នៅលើឆាកអន្តរជាតិកម្ពុជាត្រូវបានគេទទួលស្គាល់ថាជាប្រទេសមានសន្តិភាពស្ថិរភាពនិងមានការអភិវឌ្ឍឆាប់រហ័សជាកត្តាធ្វើឲ្យយើងជាជនជាតិខ្មែរមានមោទនភាពពេញមុខមាត់ មិនដូចកាលចេញទៅបំពេញបេសកកម្មនៅបរទេសក្នុងទសវត្សឆ្នាំ១៩៨០ដែលយើងមានការខ្មាសអៀនក្នុងចិត្តព្រោះតែជាជាតិសាសន៍មួយធ្លាប់មានការកាប់សម្លាប់គ្នាយ៉ាងព្រៃផ្សៃក្នុងសម័យ ប៉ុល ពត កន្លងទៅ។

អរគុណសន្តិភាពភ្ជាប់ទៅនឹងការដឹងគុណអ្នកនាំមកនូវសន្តិភាពវាមិនខុសពីអ្នកបេះផ្លែឈើត្រូវនឹកដល់អ្នកដាំនោះទេ។ សន្តិភាពពេលនេះបានមកពីការតស៊ូលះបង់ជីវិតយ៉ាងធំធេងរបស់វីរយុទ្ធជនស្នេហាជាតិនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាឆ្នាំ១៩៧៨ និងការតស៊ូរបស់ប្រជាជនកម្ពុជាដំណាក់កាលបន្តបន្ទាប់មកទៀត រហូតទទួលបានសន្តិភាពពេញលេញសព្វថ្ងៃ ដែលក្នុងនោះ **សម្តេចតេជោ ហ៊ុន សែន** ដើរតួនាទីយ៉ាងសំខាន់ ដោយយកជីវិតធ្វើដើមទុន ជាស្ថាបនិកសន្តិភាពដ៏ឧត្តុង្គឧត្តមជាមួយនឹងការប្តេជ្ញាចិត្តដ៏មោះមុតរបស់**សម្តេច**ក្នុងការការពារសន្តិភាពឲ្យស្ថិតស្ថេរជារៀងរហូត ទោះជាក្នុងតម្លៃណាក៏ដោយ៕

# អរិយធម៌ខ្មែរសម័យអង្គរ

នៅសម័យអង្គរខ្មែរមានឈ្មោះថាជាមហាអំណាចមួយនៅអាស៊ីអាគ្នេយ៍។យ៉ាងណាមិញអរិយធម៌ខ្មែរបានឡើងដល់កម្រិតកំពូល (ឧទ្ធគតភាព-apogée) នៅសម័យនោះ ជាពិសេសចាប់ពីស.វ.ទី៩ដល់ដើមស.វ.ទី១៣។ភាពរុងរឿងនេះគេអាចសម្គាល់ដោយផ្ទៃដីធំទូលាយលាតសន្ធឹងសឹងតែអស់ផ្ទៃដីឥណ្ឌូចិនទាំងមូល ដោយប្រាសាទសិលាមានចំនួនច្រើនរាប់ពាន់ប្រកបដោយក្បាច់រចនាគួរឲ្យកោតស្ញប់ស្ញែង ដោយផ្ទាំងសិលាចារឹកដ៏ច្រើនសន្ធឹកសន្ធាប់មានទាំងភាសាសំស្ក្រឹតនិងខ្មែរបុរាណឬជួនកាលមានភាសាទាំងពីរលាយចម្រុះគ្នា ដោយរូបបដិមាគ្រប់ប្រភេទនិងបុរាណវត្ថុផ្សេងៗទៀតនិងជាពិសេសដោយបរិក្ខាសង្ហរណៈដែលមានសេសសល់រហូតមកដល់សព្វថ្ងៃដូចជា បារាយ ទំនប់ទឹក បណ្ដាញជលមគ្គ ផ្លូវថ្នល់ ស្ពាន...។ ប៉ុន្តែចាប់ពីពាក់កណ្ដាលទី១នៃស.វ.ទី១៣ទៅ ការធ្លាក់ចុះដុនដាបក៏ចាប់មានបន្តិចម្ដងៗរហូតដល់ត្រូវបោះបង់រាជធានីអង្គរចោលនៅស.វ.ទី១៥ ដោយព្រះបាទចៅពញាយ៉ាត។ តទៅនេះ យើងសាកល្បងបង្ហាញរូបភាព (តាមដែលអាចធ្វើបាន) នៃសង្គមខ្មែរក្នុងសម័យរុងរឿងនោះ។

១. នយោបាយនិងរដ្ឋបាល

១[១]. ព្រះរាជា

ដោយការប្រារព្ធធ្វើពិធីទេវរាជព្រះរាជាត្រូវមានឋានៈស្មើអាទិទេព។ លុះសោយទីវង្គតទៅព្រះអង្គនឹងយាងទៅគង់នៅទេវលោក។រាជធានីរបស់ព្រះអង្គជាតំណាងនៃចក្រវាលទាំងមូលៈប្រាសាទភ្នំនៅកណ្ដាលក្រុងជានិមិត្តរូបភ្នំព្រះសុមេរុដែលគេចាត់ទុកថាជាស្នូលនៃចក្រវាលកំពែងនិងគូទឹកជានិមិត្តរូបជួរភ្នំនិងសមុទ្រដែលព័ទ្ធជុំវិញភ្នំព្រះសុមេរុ។ ប្រាសាទភ្នំសម្រាប់តំកល់លិង្គទេវរាជ អាចប្រើបានសម្រាប់តែព្រះរាជាមួយអង្គប៉ុណ្ណោះ លុះព្រះអង្គសោយទីវង្គតទៅប្រាសាទនោះនឹងក្លាយជាផ្នូរបស់ព្រះអង្គ។

លោក ជាវ តាគួន[១] ដែលបានមកទស្សនាប្រទេសខ្មែរនៅចុងស.វ.ទី១៣ (គ.ស. ១២៩៥) បានធ្វើការពិពណ៌នាពីការយាងចេញរបស់ព្រះរាជា ដែលគួរឲ្យយើងចាប់អារម្មណ៍យ៉ាងខ្លាំង។ នៅមុខក្បួនដង្ហែមានពួកទាហាន បន្ទាប់មកមានអ្នកកាន់ទង់ជ័យនិងអ្នកភ្លេង។ បន្ទាប់មកទៀតគឺពួកស្រីៗដែលមានគ្នាពី៣០០ទៅ៥០០នាក់ មានសម្លៀកបំពាក់ប្រកបដោយកំណាត់មានភ្ញីស្លឹកឈើ មានផ្កាសៀតក្នុងផ្នួងសក់ដៃកាន់ទៀនដែលនៅពេលថ្ងៃក៏ត្រូវឲ្យឆេះដែរ។តមកទៀតមានស្រីៗមួយពួកផ្សេងទៀតកាន់គ្រឿងប្រដាប់ស្ដេចធ្វើពីមាសនិងប្រាក់និងគ្រឿងលម្អទាំងអស់សុទ្ធសឹងតែជារបស់ប្លែកៗ។តពីនោះមានស្រីៗមួយពួកទៀតដែលជាអង្គរក្សដើរកាន់លំពែងនិងខែល។ តមកទៀតគឺរទេះពពែ រទេះសេះ ដែលសុទ្ធសឹងគុបតែងដោយគ្រឿងមាស។ ពួកក្សត្រនិងពួកនាយម៉ឺនសព្វមុខមន្ត្រីសុទ្ធតែជិះដំរីដែលគេមើលពីចម្ងាយមកឃើញតែក្លស់ពណ៌ក្រហមច្រើនសន្ធឹកសន្ធាប់។ បន្ទាប់ពីពួកនេះ គឺមហេសីនិងស្នំរបស់ព្រះរាជាដែលជិះគ្រែស្នែង រទេះសេះ និងដំរី ហើយមានក្លស់ជាង១០០លាបទឹកមាស។ចុងក្រោយបង្អស់គឺក្លស់បាំងព្រះរាជាមានជាងម្ភៃជាក្លស់សចម្រុះពណ៌មាសហើយមានដងក៏ស្រោបមាសទៀត។ មានដំរីដទៃទៀតជាច្រើនដើរអមដំណើរព្រះអង្គ ហើយមានទាហានដទៃទៀតតាមការពារព្រះអង្គ។ ជនណាដែលឃើញព្រះរាជាហើយត្រូវតែលុតជង្គង់ហើយអោនក្បាលដល់ដី។

១[២]. អំណាចព្រះរាជា

ដោយលិទ្ធិទេវរាជអំណាចរបស់ព្រះរាជាមានប្រភពចេញពីអាទិទេព។ ព្រះអង្គមានអំណាចលើដីធ្លី



ក្បួនដង្ហែរព្រះរាជា

ទាំងអស់៖ ការលក់ ការប្តូរ ឬការធ្វើអំណោយដីត្រូវតែមានសេចក្តីយល់ព្រមពីព្រះអង្គទើបបាន។ ព្រះរាជាមានអំណាចទូលំទូលាយណាស់ ព្រះអង្គជាអ្នកធ្វើច្បាប់ ជាអ្នកជ្រើសរើសមន្ត្រីជាន់ខ្ពស់ ជាអគ្គបញ្ជាការនៃកងទ័ព ជាអ្នកកាន់កាប់នយោបាយក្រៅប្រទេស(ពួករាជទូតបរទេសត្រូវបង្ហំគាល់ចំពោះព្រះអង្គ) ជាអ្នកកាត់សេចក្តី(ប្រសិនបើរាស្ត្រណាចង់) ជាមេសាសនា(តែងតាំងពួកបព្វជិតជាន់ខ្ពស់ និងធ្វើអធិបតីក្នុងពិធីសាសនាផ្សេងៗ) ជាអ្នកការពារប្រទេសមិនឲ្យសត្រូវយាយីខាងក្រៅ និងរ៉ាប់រងឲ្យមានសន្តិភាពនៅខាងក្នុង។ គួរកត់សម្គាល់ថា ព្រះរាជាមិនគ្រាន់តែមាននាមថាជាអគ្គបញ្ជាការតែប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គជាមេទ័ពដឹកនាំទ័ពចេញទៅប្រយុទ្ធជាមួយសត្រូវនៅក្នុងសមរភូមិតែម្តង។ អត្ថបទសិលាចារឹកជាច្រើនបានកោតសរសើរចំពោះគុណសម្បត្តិយោធារបស់ព្រះរាជាថាសុទ្ធសឹងតែមានតេជដៃខ្លាំងពូកែមានជ័យជំនះលើសសត្រូវជានិច្ច។នេះជាតម្រាប់ល្អមួយសម្រាប់ចម្បាំងវាតអំណាចក្តី វាតទឹកដីតាមលទ្ធិទេវរាជក្តី។ រូបចម្លាក់លើជញ្ជាំងប្រាសាទ(អង្គរនិងបាយ័ន) បានបង្ហាញឲ្យឃើញថា ទ័ពខ្មែរជំនាន់នោះមានពលថ្មើរជើង ពលសេះ ពលដំរី ពលជើងទឹក និងបង្ហាញថាមានពលសម្រាប់ផ្តល់ស្បៀងថែមទៀតផង។ម្យ៉ាងទៀតបើតាមរូបចម្លាក់ដដែលនោះឃើញថា ទ័ពខ្មែរសម័យនោះច្បាស់ជាមានរបៀបរៀបរយនិងវិន័យថ្លៃថ្នូរណាស់។ សិលាចារឹកវិញបានបញ្ជាក់ថាការបះបោរទាំងឡាយត្រូវបានបង្ក្រាបយ៉ាងតឹងរ៉ឹងជាទីបំផុត ឯទាហានដែលមានគុណបំណាច់ចំពោះជាតិត្រូវបានលើកតម្កើងជាអតិបរមា(ករណីកញ្ញាក់ទាំង៤របស់ស្រីន្ទកុមារបុត្រជ័យវរ្ម័នទី៧)ដោយមានការកសាងរូបបដិមា និងប្រាសាទសម្រាប់រំឭកគុណ។

ការដែលបង្ហាញឲ្យឃើញថា ព្រះរាជាសម័យអង្គរមានអំណាចទូលំទូលាយនោះ ពុំមែនមានន័យថាព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេ ព្រោះព្រះអង្គត្រូវគោរពវិន័យវណ្ណៈក្សត្រ គោរពសិក្ខាបទសាសនា បាន

សេចក្តីថាព្រះអង្គត្រូវប្រកបដោយទសពិធរាជធម៌។សិលាចារឹកព្រះគោស្លោកទី៣បាននិយាយពីព្រះបាទឥន្ទ្រវរ្ម័នទី១ថា "ស្រីឥន្ទ្រវរ្ម័នធ្វើឲ្យប្រជារាស្ត្រសំបូរសប្បាយដោយការប្រតិបត្តិនូវវិន័យទាំងបីប្រការ"។ ចំពោះប្រជារាស្ត្រព្រះរាជាតែងមានព្រះហឫទ័យអាណិតមេត្តានិងប្រកបដោយយុត្តិធម៌ជានិច្ច។ព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានខិតខំធ្វើឲ្យបានសម្រេចឧត្តមគតិនេះដោយបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីព្រះពុទ្ធសាសនា។សិលាចារឹកមន្ទីពេទ្យរបស់ព្រះអង្គបានថែងថា "ជំងឺរបស់ប្រជារាស្ត្រធ្វើឲ្យព្រះអង្គឈឺចាប់ជាងជំងឺផ្ទាល់ព្រះអង្គទៅទៀត ព្រោះថាគឺសេចក្តីឈឺចាប់សាធារណៈនេះហើយជាសេចក្តីឈឺចាប់របស់ព្រះរាជាទាំងឡាយ ពុំមែនសេចក្តីឈឺចាប់ផ្ទាល់ទេដែលធ្វើឲ្យព្រះអង្គឈឺចាប់" ។

១៣. ការបន្តរាជសម្បត្តិ

បើតាមគោលការណ៍ បុត្រច្បងអាចឡើងសោយរាជ្យស្នងព្រះបិតា ប៉ុន្តែបើគ្មានបុត្រទេញាតិណាម្នាក់អាចឡើងសោយរាជ្យបាន។ ចំពោះការបន្តរាជសម្បត្តិនេះ មានមតិពីរផ្ទុយគ្នា៖ អ្នកខ្លះយល់ថាមានតែញាតិជាប់ខ្សែខាងស្រីទៅនឹងព្រះរាជាទើបឡើងស្នងរាជ្យបាន អ្នកខ្លះទៀតយល់ផ្ទុយទៅវិញ ប៉ុន្តែបានបញ្ជាក់ថាទាល់តែជាប់ញាតិខ្សែខាងស្រីជាមួយស្តេចមុន ឬត្រូវយកក្សត្រីណាមួយក្នុងគ្រួសារស្តេចមុន ទើបអាចទទួលរាជសម្បត្តិបាន។ ក្នុងករណីដែលព្រះរាជាទទួលរាជសម្បត្តិហើយនៅក្មេងពេក នោះកិច្ចការរដ្ឋត្រូវបានព្រះគ្រូជាអ្នកទទួលខុសត្រូវ។

១៤. ពួកបរិវា

រូបចម្លាក់លើជញ្ជាំងប្រាសាទអង្គរវត្ត បង្ហាញព្រះបាទសូរ្យវរ្ម័នទី២គង់លើបល្លង្កទទួលគារវកិច្ចពីពួកបរិវាដែលមានជាអាទិពួករាជវង្សានុវង្ស មន្ត្រីជាន់ខ្ពស់ទាំងខាងស៊ីវិលនិងខាងទាហាន និងបុគ្គលិកមួយចំនួនច្រើនសន្ធឹកសន្ធាប់ណាស់។

ព្រះរាជាគង់នៅក្នុងវាំងសង់ពីឈើ។ លោក ជាវ តាគួន មានការស្ញប់ស្ញែងយ៉ាងខ្លាំងចំពោះភាពរុងរឿងនិងប្រណីតភាពនៃរាជវាំងនេះ ជាពិសេសចំពោះសាលសវនាការដែលមានបង្អួចមាស ហើយនៅខាងស្តាំនិងខាងឆ្វេងមានសសរបួនជ្រុងមានដាំកញ្ចក់តំរៀបគ្នា...។

១៥. រដ្ឋបាល

រដ្ឋបាលកណ្តាល

ការគ្រប់គ្រងរដ្ឋស្ថិតនៅក្នុងកណ្តាប់ដៃរបស់អភិជនមួយក្រុមតូច។តំណែងធំៗត្រូវបានទៅរាជវង្សានុវង្សឯតំណែងជាបុរោហិតអ្នកប្រារព្ធពិធីនៃទេវរាជព្រះរាជគ្រូត្រូវបានទៅសមាជិកត្រកូលព្រាហ្មណ៍ខ្លះៗដែលនិយមការបន្តតំណែងដោយរាប់ញាតិតាមខ្សែខាងស្រី។

វណ្ណៈក្សត្រនិងវណ្ណៈព្រាហ្មណ៍ជាវណ្ណៈខ្ពស់ដាច់ពីវណ្ណៈរាស្ត្រទូទៅ គឺជាវណ្ណៈបញ្ញាវន្ត និងជាតំណាងអរិយធម៌ឥណ្ឌា។ វណ្ណៈកំពូលទាំងពីរនេះច្រើនចងសម្ព័ន្ធមេត្រីជាមួយគ្នា។

ព្រះរាជាទ្រង់ប្រទានសវនាការពីរដងក្នុងមួយថ្ងៃសម្រាប់ដោះស្រាយកិច្ចការរដ្ឋ។ពួកនាម៉ឺនឬពួកប្រជា-រាស្ត្រដែលមានការចូលមកបង្គំគាល់ត្រូវរង់ចាំព្រះអង្គដោយអង្គុយផ្ទាល់ដី។ ពេលដែលព្រះអង្គយាងមកដល់ទាំងមន្ត្រីទាំងប្រជារាស្ត្រត្រូវលើកដៃប្រណម្យហើយអោនក្បាលដល់ដី។

នៅក្នុងរដ្ឋបាលកណ្តាល គេឃើញមានមន្ត្រីច្រើន៖ មន្ត្រីជាន់ខ្ពស់ខ្លះមានមុខងារជាទីប្រឹក្សា ខ្លះទៀតទទួលបន្ទុកធំៗនៅក្នុងវាំងឬកាន់ទ័ពនិងឈរត្រួតនៅតាមខេត្តខណ្ឌឯមន្ត្រីជាន់ទាបត្រូវបានជ្រើសរើសដោយមន្ត្រីជាន់ខ្ពស់ហើយមាននាទីនៅបម្រើពួកនេះ។ សញ្ញាសក្តិគេសម្គាល់ដោយប្រភេទត្រៃស្នែង(មាស ឬ ប្រាក់)

និងចំនួនក្លស់(ដងមាស ឬ ដងប្រាក់)។

រដ្ឋបាលភូមិភាគ

នៅក្នុងរដ្ឋបាលភូមិភាគគេឃើញមានមន្ត្រីច្រើនជាន់ច្រើនថ្នាក់ទៀតគឺមានតាំងពីអធិការ(អាជ្ញាហ្លួង?) ថៅហ្វាយខេត្ត មេស្រុក មេភូមិ មេឃ្លាំង មេខ្នង(?) មេត្រួត(មេការ?) ...។ ស្ត្រីក៏មានមុខងារសំខាន់ណាស់ដែរៈ ខ្លះធ្វើជាហោរាខ្លះទៀតធ្វើជាចៅក្រមក្នុងរាជវាំង។

ចំពោះការធ្វើសច្ចាប្រណិធានរបស់មន្ត្រីថាស្មោះត្រង់ចំពោះព្រះមហាក្សត្រនោះ គេមិនដឹងថានេះជាវិធានការទូទៅ ឬគ្រាន់តែជាមធ្យោបាយសម្រាប់ចងភ្ជាប់មន្ត្រីទៅនឹងព្រះរាជាកាលណាឡើងសោយរាជ្យមិនស្របច្បាប់។

២. សាសនានិងលទ្ធិផ្សេងៗ

២១. សាសនា

នៅសម័យអង្គរ សាសនាមានមុខងារយ៉ាងសំខាន់ក្នុងនយោបាយ ប៉ុន្តែសាសនានៃវណ្ណៈអ្នកដឹកនាំពុំដែលមានឯកភាពទេ គឺតែផ្លាស់ប្តូរទៅតាមចំណូលចិត្តរបស់បុគ្គលម្នាក់ៗៈ ព្រះរាជាខ្លះកាន់សាសនាឥសូរ ព្រះរាជាខ្លះកាន់សាសនាព្រះវិស្ណុ ព្រះរាជាខ្លះកាន់សាសនាព្រះព្រហ្ម និងព្រះរាជាខ្លះទៀតកាន់ព្រះពុទ្ធសាសនាមហាយាន។ ចំពោះហេតុការណ៍បែបនេះ លោក Sylvain Lévi ថា គឺកើតមកពីរចនាសម្ព័ន្ធនៃសង្គមខ្មែរតែម្តង។ យ៉ាងណាមិញ នៅសម័យនោះសាសនាត្រូវគេចាត់ទុកដូចទំនិញដែលគេនាំចូល ឬជាវប្បធម៌ថ្លៃថ្នូរសម្រាប់តែព្រះរាជានិងពួកអភិជន ហើយមិនសូវជ្រួតជ្រាបចូលក្នុងស្រទាប់ទាបៗនៃសង្គមដែលនៅតែថែរក្សាជំនឿដើម គឺជំនឿលើអារក្សអ្នកតាជាដើម។ លោក ជាវ តាគួន កាលមកស្រុកខ្មែរបានសង្កេតឃើញថាមានមនុស្សគោរពដុំថ្មដែលលោក Paul Pelliot ស្មានថាជាលិង្គព្រះឥសូរ តែតាមការពិតគឺថ្មអ្នកតានេះឯង។

ពីស.វ.ទី៩ដល់១១ គណៈសិវនិយមមានឧត្តមភាពលើគណៈឯទៀតៗ ព្រោះព្រះរាជាភាគច្រើនបានចាត់ទុកថាជាសាសនាសម្រាប់រដ្ឋដោយការប្រារព្ធធ្វើពិធីទេវរាជព្រះរាជាមានឋានៈស្មើអាទិទេព(ព្រះឥសូរ) ហើយមានសិវលិង្គជាតំណាងតម្កល់ក្នុងប្រាសាទភ្នំ។ ប៉ុន្តែក្នុងរយៈពេលខាងលើនេះ គេបានសង្កេតឃើញថាព្រះរាជាទាំងឡាយតែងបានយកព្រះហឫទ័យទុកដាក់និងជួយឧបត្ថម្ភចំពោះសាសនាឯទៀតដែលបានរួមរស់ជាមួយគ្នាយ៉ាងសុខដុមរមនា(Syncrétisme religieux) ដែលមានសិលាចារឹកនិងរូបបដិមាអាចបញ្ជាក់បានយ៉ាងបរិបូរ លើកលែងតែក្នុងរជ្ជកាលរបស់ព្រះបាទឧទយាទិត្យវរ្ម័នទី២ ដែលមានការបះបោរបីលើក ហើយដែលគេឃើញពួកបះបោរដើរវាយកម្ទេចសិវលិង្គនិងទេវបដិមាចោល។

នៅស.វ.ទី១២ គណៈវិស្ណុនិយមត្រូវបានព្រះបាទសូរ្យវរ្ម័នទី២ គោរពរាប់អានសម្បើមដូចមានប្រាសាទអង្គរវត្តជាសក្ខីភាពស្រាប់។ អង្គរវត្តមានទ្រង់ទ្រាយជាប្រាសាទភ្នំដដែល ប៉ុន្តែសម្រាប់តម្កល់វិស្ណុបដិមាទៅវិញ រីឯក្បាច់រចនាក៏សុទ្ធតែទៅតាមបែបវិស្ណុនិយមទាំងអស់(រូបចម្លាក់រឿងរាមកេរ្តិ៍ រឿងមហាភារតៈ រឿងកូរសមុទ្រទឹកដោះ...)។ហេតុបានជាដូចនេះព្រោះក្នុងពេលជាមួយគ្នានៅក្នុងប្រទេសឯទៀតៗក៏មានការនិយមគោរពព្រះវិស្ណុនេះដូចគ្នាដែរ។

តពីនេះទៅគេឃើញថាពុទ្ធសាសនាមហាយានដែលបាននាំចូលមកតាំងពីសម័យចេនឡា(ស.វ.ទី៨) ហើយដែលបានព្រះបាទសុរ្យវរ្ម័នទី១កាន់ម្តងរួចហើយ(ស.វ.ទី១១) ត្រូវបានព្រះរាជាលើកតម្កើងជាសាសនាសម្រាប់រដ្ឋតែម្តងជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទជយវរ្ម័នទី៧។ប្រាសាទបាយ័នដែលព្រះអង្គសាងឡើងនៅមានទ្រង់ទ្រាយជាប្រាសាទភ្នំហើយស្ថិតនៅកណ្តាលរាជធានីដដែលតែរូបតំណាងព្រះរាជាគឺជាពុទ្ធបដិមា

ទៅវិញ(ពុទ្ធរាជ)។ហេតុអ្វីបានជាមានការប្រែប្រួលយ៉ាងនេះ?ត្រង់នេះគួរគប្បីជ្រាបថាការវាយយកបានក្រុងអង្គរដោយទ័ពចាមនៅគ.ស.១១៧៧ ហើយជាលើកទីមួយផងនោះជាអន្លង់មួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ។ ប្រជារាស្ត្រទំនងជាចង់លែងជឿទៅលើប្រសិទ្ធភាពនៃលទ្ធិនេះទៀតហើយ ក៏ប៉ុន្តែពួកព្រាហ្មណ៍ជាបរិវានៅមានឥទ្ធិពលខ្លាំងក្លាណាស់នៅឡើយ ទើបព្រះបាទជយវរ្ម័នទី៧ ទ្រង់យល់ថាត្រូវតែថែរក្សាទុករបស់ចាស់ខ្លះ(មិនអាចកំចាត់ចោលភ្លាមៗបានទេ)ហើយយករបស់ថ្មីខ្លះមកប្រើដើម្បីឲ្យមានសង្ឃឹមដល់ប្រជារាស្ត្រដោយផ្សំជាតុសិរនិយមខ្លះ(ប្រាសាទភ្នំ) និងពុទ្ធិនិយមខ្លះ(ពុទ្ធរាជ)។ ដូចនេះ យើងឃើញថាពុទ្ធសាសនាមហាយានបានមកដល់ទាន់ពេលវេលាដើម្បីស្រោចស្រង់ជាតិឲ្យមានពន្លឺឡើងវិញក្រោយព្រឹត្តិការណ៍១១៧៧ ដែលព្រះបាទជយវរ្ម័នទី៧ហ៊ានយកលទ្ធិនេះមកប្រើ ព្រោះពេលនោះពុទ្ធសាសនិកក៏មានកាន់តែច្រើនណាស់ហើយ ហើយម្យ៉ាងទៀតលទ្ធិនេះជាលទ្ធិបែបមនុស្សនិយម មានទំនោរទោរទៅរកជីវភាពប្រជារាស្ត្រទូទៅ ដូចរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាសក្ខីភាពស្រាប់ ហើយដើម្បីបង្ហាញឲ្យឃើញនូវព្រះហឫទ័យមេត្តាករុណាចំពោះប្រជារាស្ត្រនេះព្រះអង្គទ្រង់បានកសាងមន្ទីរពេទ្យ១០២សម្រាប់ជនទាំងបួនវណ្ណៈចូលព្យាបាលជំងឺបានដូចៗគ្នា។ទាំងនេះសឲ្យឃើញថានៅចំពោះមុខប្រជារាស្ត្រលទ្ធិពុទ្ធសាសនាមហាយានមានសមត្ថភាពមិនចាញ់លទ្ធិទេវរាជ គឺមានសមត្ថភាពការពារស្រោចស្រង់និងបម្រើរាស្ត្របានដូចគ្នា។

តែអកុសលការផ្លាស់ប្តូរសាសនានៅតែមានបន្តទៀត។ព្រះបាទជយវរ្ម័នទី៨ត្រឡប់ទៅរកសិវនិយមវិញ ដែលជាហេតុបណ្តាលឲ្យមានប្រតិកម្មយ៉ាងខ្លាំងក្លាពីពួកព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនា រហូតដល់មានការកម្ទេច ឬកោសលុបព្រះពុទ្ធបដិមាចោល។ ស្ថានការបែបនេះទំនងជាមានសភាពពុំរ៉ាំរ៉ៃរហូតដល់បដិវត្តន៍នាយត្រសក់ផ្អែមដែលបានយកព្រះពុទ្ធសាសនាហីនយានមកជំនួសជាស្ថាពររហូតមកដល់សព្វថ្ងៃនេះ។

២ᵉ. លទ្ធិបុគ្គលនិយម

ពីស.វ.ទី៩ដល់ស.វ.ទី១២ គេឃើញមានការកសាងរូបបដិមាជាច្រើននៃទេវៈ-ទេវី ឬ ពោធិសត្វ ប៉ុន្តែរូបបដិមាទាំងនោះពុំមែនតំណាងទេវៈ-ទេវី ឬ ពោធិសត្វចំៗទាំងអស់ទេ មួយភាគធំជាតំណាងព្រះរាជា រាជវង្សានុវង្ស រាជគ្រូ ឬជនដែលមានគុណចំពោះជាតិដែលគេលើកតម្កើងឲ្យមានឋានៈស្មើទេវៈ-ទេវី ឬ ពោធិសត្វ។ ឈ្មោះនៃរូបដិមាទាំងនោះសុទ្ធតែកើតឡើងដោយការផ្សំនាមផ្ទាល់នៃបុគ្គលដែលគេគោរពជាមួយនិងទេវៈ-ទេវី ឬ ពោធិសត្វ។

គួរគប្បីសង្កេតថាលទ្ធិបុគ្គលនិយមនេះមានសភាពរុងរឿងយ៉ាងខ្លាំងនៅចុងស.វ.១២។យ៉ាងណាមិញ សិលាចារឹកតិមានអាកាសបាននិយាយថា ព្រះនាងរាជទេវី អគ្គមហេសីរបស់ព្រះបាទជយវរ្ម័នទី៧ "បានសាងនៅគ្រប់ទិសទីនូវរូបបដិមានៃព្រះបិតា ព្រះមាតា បងប្អូនញាតិមិត្តដែលព្រះនាងបានស្គាល់ច្បាស់ឬគ្រាន់តែឮគេនិយាយប្រាប់"។ម្យ៉ាងទៀតក្រោយពីព្រះនាងចូលទីវង្គតទៅ បងស្រីរបស់ព្រះនាងនាមឥន្ទ្រទេវី"បានសាងរូបបដិមារបស់ព្រះនាងយ៉ាងច្រើន របស់ព្រះរាជានិងរបស់ព្រះនាងផ្ទាល់នៅពាសពេញទីក្រុង "។

៣. សេដ្ឋកិច្ចនិងសិល្បៈ

លទ្ធិទេវរាជបានផ្តល់ឲ្យព្រះរាជានូវឋានៈអាទិទេពប៉ុន្តែអាទិទេពនេះមិនមែនស្ថិតនៅដាច់ពីមនុស្សលោកទេ ព្រះអង្គគង់នៅជាមួយមនុស្សហើយមានការមើលសុខទុក្ខរបស់ប្រជារាស្ត្រថែមទៀតផង។ ដូចនេះដើម្បីបង្ហាញឲ្យឃើញថាព្រះអង្គមានមហិទ្ធិឫទ្ធិខ្លាំងពូកែ សមឋានៈជាអាទិទេពមែននោះ ព្រះអង្គត្រូវខិតខំធ្វើយ៉ាងណាឲ្យប្រជារាស្ត្រស្គាល់នូវភាពសំបូរសប្បាយរុងរឿងយ៉ាងពិតប្រាកដ។ដោយហេតុនោះព្រះអង្គធ្វើយ៉ាងណាឲ្យកសិកម្មលូតលាស់ជាអតិបរិមា គឺត្រូវធ្វើឲ្យមានទឹកបរិបូរមិនបាច់ពឹងពាក់ទៅលើទឹកភ្លៀងទៀត ដោយការ

កសាងបារាយធំៗដែលមានសល់ខ្លះរហូតមកដល់សព្វថ្ងៃនេះផង។កិច្ចការនេះរាស្ត្របានរួបរួមគ្នាបំពេញដោយស្មោះស្មគ្រជាទីបំផុតព្រោះមានជំនឿយ៉ាងមាំទៅលើលទ្ធិទេវរាជដែលមានប្រសិទ្ធភាពអាចធ្វើការបង្រួបបង្រួមជាតិផង រំដោះប្រទេសជាតិឲ្យរួចផុតពីបរទេសផង។ បើតាមលោក ជាវ តាគួន ខ្មែរនៅសម័យនោះអាចធ្វើស្រែបានបីទៅបួនដងក្នុងមួយឆ្នាំ។ លោក Henri Stierlin អ្នកឯកទេសជាតិស្វីសម្នាក់បានគន់គូរឃើញថា នៅលើផ្ទៃដី ១,០០០គ.ម.² នៅតំបន់អង្គរគេអាចផលិតស្រូវបានក្នុងមួយឆ្នាំប្រហែល ១៥០,០០០ តោន ដែលអាចចញ្ចឹមប្រជាជនបានដល់ទៅ ៨០០,០០០នាក់ ហើយនៅសល់ ៤០% ទៀតអាចនាំយកទៅ ផ្តល់ឲ្យតំបន់ផ្សេងៗទៀត។

គឺការចម្រើនលូតលាស់ខាងសេដ្ឋកិច្ចនេះហើយដែលអនុញ្ញាតឲ្យប្រជារាស្ត្រចូលរួមក្នុងការកសាងប្រាសាទតាមតម្រូវការរបស់លទ្ធិទាំងពីរ គឺលទ្ធិទេវរាជនិងលទ្ធិបុគ្គលនិយម។ ដូចនេះ ក្នុងស្ថាបត្យកម្មសម័យនោះគេសង្កេតឃើញមានប្រាសាទពីរបែប៖

ក. ប្រាសាទភ្នំជាប្រាសាទសង់លើឿនច្រើនជាន់សម្រាប់លទ្ធិទេវរាជ( បាគង បាខែង បក្សីចាំក្រុង ប្រាសាទធំមេបុណ្យខាងកើត ប្រែរូប តាកែវ បាពួន អង្គរវត្ត បាយ័ន )។

ខ. ប្រាសាទសងទាបនឹងដីជាប្រាសាទសម្រាប់លទ្ធិបុគ្គលនិយម( ព្រះគោ លលៃ បន្ទាយឆ្មារ ព្រះខាន់ តាព្រហ្ម... )។ម៉្យាងទៀតគេបានសង្កេតឃើញថាពីរាជមួយទៅរាជមួយទៀតប្រាសាទមានទំហំកាន់តែធំឡើង ហើយកាន់តែច្រើនឡើង។

គ្រង់នេះបង្ហាញឲ្យឃើញថា ព្រះរាជាអង្គរហាក់ដូចជាបានប្រណាំងប្រជែងក្នុងការលើកកិត្យានុភាពរបស់ព្រះអង្គ។ ចំពោះប្រាសាទដូចបានរៀបរាប់រួចមកហើយនេះ ពុំមែនមានត្រឹមតែការកសាងហើយចប់នោះទេ គឺប្រជារាស្ត្រមានការផ្គត់ផ្គង់នូវគ្រឿងប្រដាប់ប្រើប្រាស់និងដង្វាយផ្សេងៗនិងមានភារៈត្រូវទៅនៅបម្រើនិងថែរក្សាប្រាសាទទាំងនោះថែមទៀត។ឧទាហរណ៍-ប្រាសាទតាព្រហ្មកសាងឡើងនៅឆ្នាំ១១៨៦ដោយព្រះបាទជយវរ្ម័នទី៧សម្រាប់ឧទ្ទិសចំពោះវិញ្ញាណក្ខន្ធនៃព្រះមាតានិងព្រះគ្រូ និងបដិមារូបឯទៀតចំនួន២៦០មានភូមិចំណុះ៣១៤០ភូមិ( សម្រាប់ផ្គត់ផ្គង់ប្រដាប់ប្រើប្រាស់និងដង្វាយផ្សេងៗ) មានមនុស្សនៅចាំបម្រើនិងថែរក្សា ៧៩,៣៦៥នាក់( ក្នុងចំណោមនោះមាន១២,៦៤០នាក់ ស្ថិតនៅក្នុងបរិវេណប្រាសាទជានិច្ច )។ គ្រឿងប្រដាប់ប្រើប្រាស់ជាដង្វាយមាន៖ ចានមាសមួយទម្ងន់ជាង៥តោន ចានប្រាក់មួយទម្ងន់ដូចគ្នា ពេជទាំងគ្រាប់ធំ៣៥ គ្រាប់ត្បូងមុក្តា៤០,៦២០គ្រាប់ត្បូងយ៉ាងល្អ៤,៥៤០គ្រាប់ផ្តិលមាសធំមួយនាំងស្រុកចិន៩៦៧គ្រែធ្វើដោយសំពត់ល្អ៥១២ ក្លស់៥២៣។ ចំពោះស្បៀងអាហារមាន៖ អង្ករ ស្ករ ទឹកដោះគោ ប្រេង ទឹកឃ្មុំ ក្រមួន ខ្លឹមចន្ទន៍ កប៉ូរ គ្រឿងចីវរ។ នេះចំពោះប្រាសាទតែមួយផងឃើញថាមានការប្រើប្រាស់កម្លាំងមនុស្សនិងទ្រព្យសម្បត្តិអស់យ៉ាងសន្ធឹកសន្ធាប់ទៅហើយ ចុះបើខ្មែរយើងមានប្រាសាទដល់ទៅរាប់ពាន់ តើតម្រូវការទាំងខាងកម្លាំងមនុស្សទាំងខាងទ្រព្យសម្បត្តិមានដល់ប៉ុន្មាន? ចំពោះបញ្ហានេះ ប្រវត្តិវិទូជាច្រើនបានចាត់ទុកថា ការកសាងប្រាសាទរួមទាំងចម្បាំងដ៏វែងឆ្ងាយ( សូរ្យវរ្ម័នទី២ វាយយួនផង ចាមផង មនផង ) ជាកត្តាមួយនៃការធ្លាក់ចុះនៃអរិយធម៌អង្គរនេះឯង។

## III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត

### ១- សេចក្តីព្រាងផែនការជាតិ៥ឆ្នាំស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩-២០២៣



សេចក្តីព្រាងផែនការជាតិ៥ឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩-២០២៣រៀបចំឡើងដោយអគ្គលេខាធិការដ្ឋាននៃអជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីអនុវត្តជាបន្តនូវរាល់សកម្មភាពទាំងឡាយដែលកំពុងអនុវត្តនិងសកម្មភាពដែលពុំទាន់បានអនុវត្តក្នុងផែនការជាតិ៣ឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៦-២០១៨ ជាពិសេសកម្មវិធីថ្មីៗមួយចំនួន ដែលឆ្លើយតបទៅនឹងសភាពការណ៍វិវត្តនៃគ្រឿងញៀនទាំងនៅក្នុងប្រទេស ក្នុងអនុតំបន់ ក្នុងតំបន់ និងទាំងនៅលើពិភពលោកនាពេលបច្ចុប្បន្ន។

ការត្រួតពិនិត្យគ្រឿងញៀនធ្វើឲ្យបទល្មើសគ្រប់ប្រភេទមានការថយចុះនិងការចូលរួមយ៉ាងសកម្មជាមួយប្រទេសទាំងនៅក្នុងតំបន់និងពិភពលោកក្នុងការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធ គឺជាគោលនយោបាយអាទិភាពមួយដែលមានចែងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា សម្រាប់ការកសាងនិងការពារមាតុភូមិឆ្នាំ២០១៨-២០២៣ ហើយក៏មានចែងផងដែរនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌និងប្រសិទ្ធភាពកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យនាឆ្នាំ២០៥០ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក្នុងការរួមចំណែកធ្វើឲ្យបរិស្ថានគ្របដណ្តប់សម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងមូលបានល្អប្រសើរ ជាពិសេសក្នុងការលើកកម្ពស់សណ្តាប់ធ្នាប់សាធារណៈ។

ដោយឡែក ផ.យ.អ.ក. ២០១៩-២០២៣ ដែលត្រូវរៀបចំឡើងសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក៏ដូចជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏មានកំណត់អំពីគោលនយោបាយ យុទ្ធសាស្ត្រជាអាទិភាពសំខាន់ៗរួមទាំងសកម្មភាពកម្មវិធី និងគម្រោងនានាដែលក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តទៅតាមវិស័យទទួលខុសត្រូវរៀងៗខ្លួននៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា ដែលក្នុងនោះក៏មានការប្រយុទ្ធប្រឆាំងគ្រឿងញៀនមួយផងដែរ។

សេចក្តីព្រាងផែនការជាតិនេះ ចែកចេញជា៦ជំពូក និងមានឧបសម្ព័ន្ធចំនួន២។ ជំពូកទី១ ចែងអំពីស្ថានភាពទូទៅរួមមាន ស្ថានភាពភូមិសាស្ត្រនិងប្រជាជន របបនយោបាយ រចនាសម្ព័ន្ធរដ្ឋបាល សេដ្ឋកិច្ចនិងសង្គម និងស្ថានភាពគ្រឿងញៀន( ទាំងលើសកលលោកនិងក្នុងប្រទេស) ជំពូកទី២ ចែងពីសមិទ្ធផល ចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈម ក្នុងការអនុវត្តផែនការជាតិ៣ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៦-២០១៩។ ជំពូកទី៣ ស្តីពីផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣។ ជំពូកនេះកំណត់ពីគោលការណ៍ គោលបំណង និងយុទ្ធសាស្ត្រសម្រាប់អនុវត្តផែនការជាតិ រួមមាន : ១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន ២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ៣.ការពង្រឹងប្រសិទ្ធភាពព្យាបាល ស្តារនីតិសម្បទា និងធ្វើ

សមាហរណកម្ម ៤.ការពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ និង៥.ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលដូចគ្នានឹងផែនការជាតិឆ្នាំ២០១៦-២០១៨ដែរ ហើយជាមួយគ្នានេះ ក៏មានកំណត់វិធានការយុទ្ធសាស្ត្រចំនួន៧ដើម្បីអនុវត្តបន្តយុទ្ធសាស្ត្រទាំង៥នេះទៀតដែលរួមមាន៖

១.ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងក្រោមជាតិ

២.ការអប់រំផ្សព្វផ្សាយបង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

៣.ការព្យាបាលស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈបំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

៤.ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

៥.ការត្រួតពិនិត្យសារធាតុគីមីផ្សំ

៦.កិច្ចសហប្រតិបត្តិអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៧.កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា។

ជំពូកទី៤ស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ។នៅក្នុងជំពូកនេះមានការរៀបរាប់អំពីកម្មវិធីនិងសកម្មភាពសម្រាប់អនុវត្តកម្មវិធីទាំងនោះទៅតាមវិធានការយុទ្ធសាស្ត្រនីមួយៗខាងលើ។ជំពូកទី៥ ស្តីពីតម្រូវការធនធាននិងហិរញ្ញវត្ថុដែលប៉ាន់ប្រមាណចំនួន ២៣២ ៦៦៣ ២០០ ០០០ រៀល (ប្រហាក់ប្រហែលនឹង ៥៨ ១៦៥ ៨០០ ដុល្លារអាមេរិច)។ ជំពូកទី៦ ចុងក្រោយ ស្តីពីការត្រួតពិនិត្យផែនការជាតិ រួមមាន ការតាមដាន ការវាយតម្លៃ និងការកែសម្រួលផែនការ។

សេចក្តីព្រាងផែនការជាតិមានឧបសម្ព័ន្ធចំនួន២គឺ១.តារាងសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ និង២.តារាងតម្រូវការថវិកាសម្រាប់ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩-២០២៣។

សេចក្តីព្រាងផែនការជាតិ៥ឆ្នាំ ស្តីពីត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩-២០២៣ ត្រូវបានបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី និងត្រូវបានដាក់ឆ្លងកិច្ចប្រជុំបច្ចេកទេសនៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០២០ ដឹកនាំដោយឯកឧត្តម **កែវ រិមិត្រ** តំណាងក.ស.រ. និងឯកឧត្តម **អ៊ុំ ម៉ុនធឿន** តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធាន ដោយមានការចូលរួមពីឯកឧត្តម **ឈិន សុខុន** រដ្ឋលេខាធិការស្តីទីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **មាស ធិរិទ្ធ** អគ្គលេខាធិការ អ.ជ.ប.ញ. និងសហការី រួមទាំងសមាជិក ក.ស.រ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី មួយចំនួនទៀតផងដែរ។

អង្គប្រជុំបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាអស់រយៈពេលពេញមួយថ្ងៃទាំងព្រឹកទាំងល្ងាចទៅតាមជំពូកនៃសេចក្តីព្រាង និងទៅតាមចំណុចនីមួយៗនៅក្នុងជំពូក។ ជាលទ្ធផលអង្គប្រជុំបានឯកភាពគ្នាបន្ថែមពាក្យពេចន៍ខ្លះឲ្យបានពេញលេញមានដូចជានៅសេចក្តីផ្តើមបន្ទាត់ទី២បន្ថែមពាក្យ“ស្របច្បាប់”នៅពីក្រោយពាក្យ “ការបង្វែរសារធាតុគីមីផ្សំ” ពាក្យ “កិល្បការីនី” និង “ពិធីការិនី” នៅទំព័រ៩បន្ទាប់ពីពាក្យ “សិប្បករ” និង “ពិធីការិនី” ជាដើម កែតម្រូវតួលេខខ្លះ និងកែខ្លឹមសារចំណុចខ្លះឲ្យបានត្រឹមត្រូវ និងសមស្រប។

ចំពោះទម្រង់ជារួម អង្គប្រជុំអាចទទួលយកបាន ទោះបីជាមានការខុសឆ្គងខ្លះពីការណែនាំជាគោលការណ៍ក៏ដោយព្រោះនេះជាការអនុវត្តតាមគំរូនៃផែនការចាស់ឆ្នាំ២០១៦-២០១៩ហើយសេចក្តីព្រាងនេះក៏បានដាក់ជូនកិច្ចប្រជុំពិនិត្យពិភាក្សា ផ្តល់យោបល់ និងកែសម្រួលជាច្រើនលើក ច្រើនសាមកហើយដែរ៕

*ក.ស.រ. - ក្រុម ១*

## ២- សេចក្តីព្រាងច្បាប់ស្តីពី

# ការការពាររុក្ខជាតិ និងភូតគាមអនាម័យ

កំណើននៃការប្រើប្រាស់ផលិតផលកសិកម្មបានកើនឡើងជានិច្ចស្របទៅនឹងកំណើនប្រជាសាស្ត្រ និងកំណើនប្រាក់ចំណូលរបស់ប្រជាជនយើងម្នាក់ៗ ប៉ុន្តែសកម្មភាពពាណិជ្ជកម្ម ការនាំចេញការនាំចូលផលិតផលកសិកម្មនិងផលិតផលរុក្ខជាតិត្រូវតែធានាឱ្យបាននូវការការពារផលប្រយោជន៍របស់កសិករ និងការគាំទ្រសកម្មភាពពាណិជ្ជកម្មផលិតផលកសិកម្មផងដែរ។ដើម្បីទប់ស្កាត់ការផ្ទុកនូវសមាសភាពចង្រៃនិងការឆ្លងរាលដាលទូទាំងប្រទេស ព្រះរាជាណាចក្រកម្ពុជាបានពិនិត្យនិងកំណត់នូវភាពចាំបាច់ដើម្បីអនុវត្តកាតព្វកិច្ចជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិការការពាររុក្ខជាតិឆ្នាំ១៩៩៧ ដើម្បីអនុវត្តឱ្យបានឯកភាពគ្នាលើបទដ្ឋានបច្ចេកទេសទៅលើការងារភូតគាមអនាម័យជាលក្ខណៈស្តង់ដាអន្តរជាតិនិងបានបំពេញលក្ខខណ្ឌអាស៊ាននៃពិធីសារទី៨ (Protocol 8) ស្តីពីការសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ និងលក្ខខណ្ឌតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលក្នុងនោះព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តកិច្ចព្រមព្រៀងស្តីពីអនាម័យនិងភូតគាមអនាម័យ (SPS agreement) ជាចាំបាច់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្តីព្រាងច្បាប់នេះឡើងដោយផ្អែកលើច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញនិងសេវា គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករបស់រាជរដ្ឋាភិបាលឆ្នាំ២០១០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០១៤-២០១៨ និងអនុក្រឹត្យលេខ២៧អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញនាំចូលដើម្បីសម្រួលពាណិជ្ជកម្មនិងពង្រឹងភាពប្រកួតប្រជែង។ សេចក្តីព្រាងច្បាប់នេះមាន១៥ជំពូក ចែកចេញជា១២២មាត្រា និងមានឧបសម្ព័ន្ធដែលជាសន្ទានុក្រមមាន ៤៥ចំណុច។

គោលបំណងនៃច្បាប់នេះគឺធានាការគ្រប់គ្រងការការពាររុក្ខជាតិនិងភូតគាមអនាម័យតាមគោលដៅគ្រប់គ្រងសុខភាពរុក្ខជាតិដោយអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ដើម្បីការពារធនធានរុក្ខជាតិគ្រប់ប្រភេទព្រមទាំងទប់ស្កាត់ការបង្ការការរាលដាលឆ្លងការរាតត្បាតពីសំណាក់សមាសភាពចង្រៃហើយដែលមានវិសាលភាពគ្របដណ្តប់ទៅលើរាល់សកម្មភាពការការពាររុក្ខជាតិនិងភូតគាមអនាម័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អត្ថប្រយោជន៍នៃសេចក្តីព្រាងច្បាប់នេះគឺការពារផលប្រយោជន៍របស់កសិករតាមរយៈការគ្រប់គ្រងការការពាររុក្ខជាតិ និងការអនុវត្តវិធានការភូតគាមអនាម័យនិងការការពារសុខភាពសាធារណៈ គាំទ្រយុទ្ធសាស្ត្រផលិតកម្មកសិកម្មគាំទ្រសកម្មភាពពាណិជ្ជកម្មផលិតផលកសិកម្មនិងការនាំចេញផលិតផលរុក្ខជាតិនិងការការពារផលិតផលរុក្ខជាតិនិងធនធានរុក្ខជាតិក្នុងស្រុកព្រមទាំងការពារធនធានជីវចម្រុះ។

សេចក្តីព្រាងច្បាប់នេះបានឆ្លងកិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំបច្ចេកទេសចំនួន ១៥លើក(១៨ តុលា ២០១៧ ដល់ ១៦ វិច្ឆិកា ២០១៧) កិច្ចប្រជុំអន្តរក្រសួងចំនួន៦លើក(១២ ធ្នូ ២០១៧ ដល់ ៨ កុម្ភៈ ២០១៨) និងកិច្ចប្រជុំអន្តរក្រសួងចុងក្រោយនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ដោយបានបញ្ចប់ចំនួន១២ជំពូកនិង១០២មាត្រា។ជំពូកទី១៣ស្តីពីទោសប្បញ្ញត្តិអង្គប្រជុំសម្រេចជូនក្រសួងសាមីនិងក្រសួងយុត្តិធម៌រួមគ្នារៀបចំរួចរាយការណ៍ជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីបន្តទៅតាមនីតិវិធី៕

*ក.ស.រ. - ក្រុម ២*

## ៣- សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពី

# ការទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៩-២០២៣



ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ស្ថិតនៅក្នុងក្របខ័ណ្ឌគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ទាំងក្របខ័ណ្ឌជាតិ ទាំងក្របខ័ណ្ឌអន្តរជាតិ។ ក្នុងក្របខ័ណ្ឌជាតិ មាត្រា៣៨ មាត្រា៤៥ និងមាត្រា៤៨នៃរដ្ឋធម្មនុញ្ញ ចែងអំពីគោលការណ៍ជាមូលដ្ឋាន ដើម្បីការពារស្ត្រីប្រឆាំងនឹងការរើសអើង អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី។ផ្អែកលើរដ្ឋធម្មនុញ្ញយើងកសាងបានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ (២០០៨) ព្រមទាំងច្បាប់និងគោលនយោបាយជាតិសំខាន់ៗផ្សេងទៀតដែលធានាដល់ការពង្រឹងសមភាពយេនឌ័រ នៅក្នុងគ្រួសារ កន្លែងធ្វើការ និងនៅក្នុងសង្គមជាតិ។

ក្នុងក្របខ័ណ្ឌអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិមួយចំនួនដើម្បីការពារសិទ្ធិស្ត្រី ដូចជាអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ក្នុងឆ្នាំ១៩៩២ និងពិធីសារតាមជម្រើសឆ្នាំ២០១០ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(CRC) ក្នុងឆ្នាំ១៩៩២ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ(UNCRPP) សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច(UNDRIP) ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារជាដើម។

ក្នុងក្របខ័ណ្ឌអាស៊ាន ព្រះរាជាណាចក្រកម្ពុជាបានចូលរួមប្តេជ្ញាចិត្តនៅថ្នាក់តំបន់ដើម្បីការពារសិទ្ធិស្ត្រី មានសេចក្តីប្រកាសអាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០០៤សេចក្តីប្រកាសអាស៊ានស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារឆ្នាំ២០០៤ សេចក្តីប្រកាសអាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារឆ្នាំ២០១៣ ផែនការសកម្មភាពប្រចាំតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារឆ្នាំ២០១៧ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងអំពើការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារឆ្នាំ២០១៥ជាដើម។

ផ្អែកលើស្មារតីនិងលិខិតូបករណ៍ទាំងអស់នេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានរៀបចំនូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី១ឆ្នាំ២០០៩-២០១៣ដែលត្រូវបានអភិវឌ្ឍបន្ថែមទៀតមកដល់ការកសាងផែនការជាតិលើកទី៣ឆ្នាំ២០១៩-២០២៣ដែលកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយបន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងអនុវត្ត និងការវាយតម្លៃផែនការលើកទី១និងទី២ ដែលបង្ហាញនូវសមិទ្ធផលសំខាន់ៗជាច្រើនក្នុងការបង្ការ ទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី រួមជាមួយបញ្ហាប្រឈមសេសសល់និងបញ្ហាប្រឈមថ្មីៗមួយចំនួនត្រូវបន្តដោះស្រាយដូចជាកង្វះធនធានកិច្ចសម្របសម្រួលក្នុងការផ្តល់សេវានៅមានកម្រិត និងមិនទាន់បានទូលំទូលាយជាដើម។

សេចក្តីព្រាងផែនការសកម្មភាពជាតិលើកទី៣នេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់៤លើកជាពិសេស ក្នុងកិច្ចប្រជុំពិគ្រោះយោបល់កម្រិតក្រុមការងារបច្ចេកទេសឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ(សមាសភាពមកពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល)។ បញ្ហាសំខាន់ៗចំនួន៣ដែលត្រូវមានកំណត់ជាបញ្ហាអាទិភាពក្នុងផែនការសកម្មភាពជាតិ មាន : ១-អំពើហិង្សាក្នុងគ្រួសារ ២-ការរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទ និង៣-អំពើហិង្សាលើស្ត្រីដែលកើតមានក្នុងក្រុមស្ត្រីងាយរងគ្រោះ។

ដើម្បីធ្វើឲ្យសម្រេចបាននូវការកាត់បន្ថយអំពើហិង្សាលើស្ត្រីក្នុងអាទិភាពសំខាន់ៗដែលកំណត់ខាងលើផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៩-២០២៣ដាក់ចេញនូវយុទ្ធសាស្ត្រចំនួន៤ គឺ : ១-ការបង្ការទប់ស្កាត់ ២-កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ ៣-ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ និង៤-ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ។

សេចក្តីព្រាងត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ដឹកនាំដោយសហប្រធាន ឯកឧត្តម **ឆយ អូន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងមានលោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនិងសហការីជាអ្នកការពារសេចក្តីព្រាង។ អង្គប្រជុំបានផ្លាស់ប្តូរយោបល់ផុលផុសលើខ្លឹមសារសេចក្តីព្រាង ដោយឡែកលើទស្សនៈត្រឹមត្រូវអំពីពាក្យ "ស្ត្រី"ដែលត្រូវប្រើសម្រាប់គ្រប់វ័យទាំងអស់របស់នារី លើបញ្ហាអាទិភាព និងទម្រង់ផ្សេងៗទៀតនៃអំពើហិង្សាដែលត្រូវកំណត់និយមន័យឲ្យបានច្បាស់លាស់យកពីប្រភពច្បាប់ផ្សេងៗ ដើម្បីងាយស្រួលដល់ការអនុវត្តការងារ។ ចំពោះយុទ្ធសាស្ត្រនីមួយៗ កិច្ចប្រជុំបានពិភាក្សាភ្ជាប់ទៅនឹងតារាងអនុវត្តការងារ (ម៉ាទ្រិក) ដែលរៀបចំឡើងដោយស្ថាប័នសាមី ជាពិសេសគឺការដាក់ឲ្យមានសូចនាករជាក់លាក់នៅក្នុងសកម្មភាពមួយចំនួនក្នុងម៉ាទ្រិក ដើម្បីប្រើជាគោលដៅសម្រាប់ការអនុវត្ត ព្រមទាំងសម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃនៅពាក់កណ្តាលអាណត្តិ ឬពេលចប់ផែនការ៕

*ក.ស.វ. - ក្រុម ៣*

**គតិបណ្ឌិត**

" មនុស្សចាស់ស៊ីអំបិលច្រើនជាងអង្ករ

គង់ស្គាល់អាក្រក់ល្អច្រើនជាងក្មេង។ "

សម្តេចព្រះធម្មលិខិត - **ល្វី ឯម ខេមរឧបញ្ញោ**

# IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៩




របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំឆ្នាំ២០១៩** ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គ-លេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➢ អតិផរណាឆ្នាំ២០១៩ មានអត្រាស្មើនឹង១,៩% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃលើសអត្រានេះមាន ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ សម្លៀកបំពាក់និងស្បែកជើង ព្រមទាំងភោជនីយដ្ឋាន។

តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ។

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ ២០១៩ | អត្រារួម ចំណែក | អតិផរណាឆ្នាំ ២០១៨ |
|---|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១,៩% | ១០០% | ២,៥% |
| ១ | ភោជនីយដ្ឋាន | ៦,២% | ១៨,៨% | ៥,៩% |
| ២ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ៥,៤% | ៤,៥% | ១,៩% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ២,៥% | ១,៧% | ២,១% |
| ៤ | ម្ហូបអាហារ | ២,១% | ៤៧,២% | ២,៥% |
| ៥ | ទំនិញ និងសេវាកម្មផ្សេងៗ | ១,៧% | ២,០% | ២,៨% |
| ៦ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងៗ | ១,៣% | ១១,២% | ១,៣% |
| ៧ | គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | ១,៣% | ១,៨% | ០,៤% |
| ៨ | សុខាភិបាល | ១,២% | ៣,៣% | ១,៥% |
| ៩ | ការកម្សាន្ត និងវប្បធម៌ | ០,៨% | ១,១% | -០,៣% |
| ១០ | ការសិក្សា | ០,៥% | ០,៣% | -០,១% |
| ១១ | ទូរគមនាគមន៍ | -០,៧% | -០,៤% | -០,៧% |
| ១២ | ការដឹកជញ្ជូន | -២,៣% | ១៤,៣% | ២,៩% |
| | ក្នុងនោះប្រេងសាំង | -៨,៧% | -២២,៣% | ៦% |

⇨ក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះមាន ក្រុមដឹកជញ្ជូន និង ក្រុមទូរគមនាគមន៍។

តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ២០១៧-២០១៩(ជាកំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៩ | ខែដូចគ្នាឆ្នាំមុន | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |
| ២០១៨ | ខែដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| ២០១៧ | ខែដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |

⇨ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ឧស្ម័ន៥,៨% ត្រីស្រស់៣,៣% អង្ករ៣,៣% សាច់មាន់ស្រស់៣,២% ផ្លែឈើ២,៤% និងបន្លែ២,៣%។

➢**អត្រាប្តូរប្រាក់:**

⇨ប្រាក់រៀលមានការធ្លាក់ថ្លៃ១,៤%ធៀបនឹងប្រាក់ដុល្លារអាមេរិក ធ្លាក់ថ្លៃ៩,៧%ធៀបនឹងប្រាក់បាត និងធ្លាក់ថ្លៃ ១,១%ធៀបនឹងប្រាក់ដុង ប៉ុន្តែមានការឡើងថ្លៃ០,២%ធៀបនឹងប្រាក់យ៉ន់។ នាចុងឆ្នាំ២០១៩ អត្រាប្តូរប្រាក់រៀល មានស្ថានភាពដូចខាងក្រោម:

- ប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានអត្រា៤០៧៥៛/ដុល្លារ
- ប្រាក់រៀលធៀបនឹងដុងវៀតណាមមានអត្រា០,១៧៦៛/ដុង
- ប្រាក់រៀលធៀបនឹងបាតថៃមានអត្រា១៣៦៛/បាត
- ប្រាក់រៀលធៀបនឹងយ៉ន់ចិនមានអត្រា៥៨៣៛/យ៉ន់។

## ២. ស្ថានភាពថវិកាជាតិ

➢យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១៩នេះ អនុវត្តបានចំនួន ២៥ ៦៥២,៥ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៦ ៤១៣,១លានដុល្លារ) ស្មើនឹង ១២៨% នៃផែនការ ក្នុងនោះចំណូលចរន្ត ២៥ ០២២,៥ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៦ ២៥៥,៦ លានដុល្លារ) ស្មើនឹង ១២៨% នៃផែនការ និង ចំណូលមូលធន៦៣០,០ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១៥៧,៥លានដុល្លារ) ស្មើនឹង ១៤២% នៃផែនការ ។

➢ បើធៀបនឹងឆ្នាំ២០១៨ ចំណូលថវិកាជាតិកើនឡើង ២៨,៥% ក្នុងនេះ ចំណូលចរន្តកើនឡើង ២៨,០% និង ចំណូល មូលធនកើនឡើង៥៥% ។

⇨ការកើនឡើងនៃចំណូលចរន្តជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង២៨,៣% និងចំណូលមិនមែនសារពើពន្ធ កើនឡើង២៦,២%។

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០១៨ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០១៨ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ១២៩% | +២៨,៣% | **ចំណូលមិនមែនសារពើពន្ធ** * | ១១៨% | +២៦,២% |
| ✓**ពន្ធ និងអាករគយ** ** | ១៨៩% | +៣០,៤% | ✓កាស៊ីណូ | ១៥២% | +១០៥,៧% |
| –ពន្ធគយ (របបនាំចូល) | ១៤៤% | +៣១,២% | ✓ចំណូលពីអជ្ញាបណ្ណក្នុងស្រុក | ១៦០% | +៤៩,០% |
| –អាករពិសេសលើរបបនាំចូល | ២៣៩% | +៣៣,៩% | ✓កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំ | ៨៧% | +២,៧% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១៦៨% | +២៨,៨% | ចេញ | ៦១% | +១២,០% |
| –អាករនាំចេញ | ១០១% | -៥,១% | ✓នេសាទ | ១០០% | +៨៦,២% |
| –អាករបន្ថែមលើគេលសិលា | ១៣៦% | +២២,៧% | ✓ រុក្ខាប្រមាញ់ | ៨៩% | +២០,៨% |
| ✓**ចំណូលពន្ធដារ** *** | ១២០% | +២៩,០% | ✓សម្បទានរ៉ែ | ៨៦% | +៥០,៣% |
| –ពន្ធលើប្រាក់បៀវត្ស | ៩៦% | +២១,៩% | ✓អាកាសចរណ៍ស៊ីវិល | ៨០% | -១១,១% |
| – ពន្ធលើប្រាក់ចំណូល | ១១៩% | +២៨,៧% | ✓ផលទុនទេសចរណ៍ | ៤០% | -៤០,១% |
| – អាករលើតម្លៃបន្ថែម | ១០៩% | +២៧,៣% | ✓ ត្រួតពិនិត្យគុណភាពផលិតផល | ៩០% | +២០,១% |
| –អាករពិសេស | ១១៣% | +៣០,៤% | ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | | |
| –ពន្ធថវិកាខេត្ត-រាជធានី | ១៥៥% | +៣៥,១% | | | |

* តួលេខរតនាគាជាតិ     * *តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ     * * *តួលេខអគ្គនាយកដ្ឋានពន្ធដារ

➢ចំណាយថវិកាជាតិក្នុងឆ្នាំ២០១៩ អនុវត្តបាន ១៨ ៧៤០,៣ ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ៤ ៦៨៥,១ លានដុល្លារ) ស្មើនឹង ៩២% នៃផែនការ ក្នុងនោះ ចំណាយចរន្ត ១៤ ៩៥២,១ ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ៣ ៦៣៨,០ លានដុល្លារ) ស្មើនឹង ៨៣% នៃផែនការ និងចំណាយមូលធន ៣ ៨១២,៩ ប៊ីលានរៀល ស្មើនឹង ១៤០% នៃផែនការ។

➢បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង១១,៤% ក្នុងនោះចំណាយចរន្តកើនឡើង៣,៤% និងចំណាយមូលធនកើនឡើង៣៨,៦%។

➢ជាលទ្ធផលថវិកាជាតិនាឆ្នាំ២០១៩ មានអតិរេកចំនួន ៦ ៩១២,២ ប៊ីលានរៀល (គិតជាដុល្លារអាមេរិក ១ ៧២៨,១ លានដុល្លារអាមេរិក)។ ប៉ុន្តែគួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលបានឆ្លងកាត់រតនាគារជាតិតែប៉ុណ្ណោះ។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៩មានសូចនាកររូបិយវត្ថុដូចខាងក្រោម ៖

⇨រូបិយវត្ថុ *M2* មានចំនួន ១០៤ ៣២៤,៧ ប៊ីលានរៀល កើនឡើង ១៨,០% ធៀបនឹងឆ្នាំ២០១៨។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៨** (% នៃរូបិយវត្ថុទូទៅ*M2*)




**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៩**




⇨សមាសធាតុរូបិយវត្ថុ បង្ហាញថា ការប្រើប្រាស់ប្រាក់រៀលមានការកើនឡើង បើធៀបឆ្នាំ២០១៩និង២០១៨: រូបិយវត្ថុក្រៅធនាគារកើនឡើងពី១០,៥% នៃM2 ក្នុងឆ្នាំ២០១៨ទៅ ១១,៧% ក្នុងឆ្នាំ២០១៩ ឯប្រាក់បញ្ញើជារូបិយបណ្ណបរទេសថយចុះពី ៨៤,៨% មក ៨២,៧% នៃM2។

⇨តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន (២០១៥-២០១៩)

| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|
| *M2* | +១៤,៧% | +១៧,៩% | +២៣,៨% | +២៤,០% | +១៨,០% |
| *សមាមាត្រ M2 ក្នុងផសស* | ៦៧% | ៧២% | ៨០% | ៨៩% | ៩៦% |
| *M1* | +៦,៩% | +៧,២% | +២៩,៦% | +៨,៥% | +៣៦,៤% |
| *សមាមាត្រ M1 ក្នុងផសស* | ៩,២% | ៩% | ១០,៥% | ១០,៣% | ១២,៨% |
| រូបិយវត្ថុក្រៅធនាគារ | +៥,៤% | +៨,៩% | +២៨,២% | +១១,៥% | +៣១,៣% |
| ប្រាក់បញ្ញើចរន្ត | +១៨,១% | -៥,៣% | +៤០,៩% | -១៣,៨% | +៨៤,៨% |
| រូបិយវត្ថុផ្សេងៗ | +១៦,១% | +១៩,៦% | +២២,៩% | +២៦,៤% | +១៥,៥% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +៤២,២% | +៥៤,០% | +៩,៦% | +២២,៧% | +២៨,៨% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +១៥,៣% | +១៨,៣% | +២៣,៦% | +២៦,៥% | +១៥,០% |

⇨ក្នុងឆ្នាំ២០១៩ រូបិយវត្ថុទូទៅ*M2* មានចំនួនប្រហែល ៩៦%នៃផសស ប៉ុន្តែ**សមមាត្រ***M1* ក្នុងផសស មានត្រឹមតែ ១២,៨% ប៉ុណ្ណោះ។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន ១៨ ៧៦៣ លានដុល្លារកើនឡើង២៨,៣%ធៀបនឹងឆ្នាំ ២០១៨។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធខាងលើ អាចធានាការនាំចូលបានចំនួន ៨ ខែ។

➢ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន ៣២ ៦៣៥,០ ប៊ីលានរៀលកើនឡើង៦,៨% បើធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ១០៧ ៥៩៤,០ ប៊ីលានរៀលកើនឡើង ២៧,០%ធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(មិនទាន់មានតួលេខ)

➢**អត្រាការប្រាក់ប្រចាំឆ្នាំ**:

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ ២០១៩* | *អត្រាឆ្នាំ ២០១៨* | %∆(២០១៩/២០១៨) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,១% | ៥,១% | -១៩,៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ៨,៦% | ១២,២% | -២៩,៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៤% | ៣,៤% | ២,៧% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,០% | ៨,៥% | -៦,០% |
| កម្ចីជារៀលនៅហាត្ថកសិករ | ១៧,៨% | ១៧,៩% | -០,៣% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៧,៨% | ០,៩% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,១% | ១៧,០% | -៥,០% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

➢***កសិកម្ម:***

⇨ផលិតផលស្រូវប្រចាំឆ្នាំ២០១៩ មានចំនួន ១០ ៨៨៥ ពាន់តោន មានការថយចុះ០,១%ធៀបនឹងឆ្នាំ២០១៨ ដែលមានទំហំ ១០ ៨៩២ ពាន់តោន។ ការថយចុះនេះ ជាចម្បងបណ្តាលមកពីការថយចុះនៃផ្ទៃដីដាំដុះ ពី ៣ ៣៣៦ ពាន់ ហិកតា នាឆ្នាំ២០១៨ មក ៣ ៣២៩ ពាន់ហិកតា នាឆ្នាំ២០១៩ រីឯទិន្នផលស្រូវមានការថយចុះពី ៣,៣៥៣ តោន/ហិកតានាឆ្នាំ២០១៨ មក ៣,៣៣៥ តោន/ហិកតានាឆ្នាំ២០១៩។

ផលិតផលស្រូវ (ពាន់តោន)




**ទិន្នផលស្រូវ (តោន/ហិកតា)**




⇨ក្នុងឆ្នាំ២០១៩ ផលិតផលកៅស៊ូមានចំនួន២៨៧,៦ពាន់តោន កើនឡើង ៣០,៧% ធៀបនឹងឆ្នាំ២០១៨។ ផ្ទៃដីចៀរជ័រមានចំនួន២៥០,៥ ពាន់ហិកតាកើនឡើង២៤,០%ធៀបនឹងឆ្នាំ២០១៨ និងផ្ទៃដីដាំដុះសរុបមាន ៤០៥,៧ ពាន់ហិចតាថយចុះ ៧,១%ធៀបនឹងឆ្នាំ២០១៨។

⇨ ផលិតកម្មនេសាទឆ្នាំ២០១៩ មានចំនួន ៩០៨,៥ ពាន់តោនមានការថយចុះ០,២%ធៀបនឹងឆ្នាំ២០១៨។

## ➢ឧស្សាហកម្ម

⇨ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៩ ៣២៤,៥ លានដុល្លារអាមេរិក មានការកើនឡើង១១,៣% ធៀបនឹងឆ្នាំ ២០១៨។

⇨ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន ៣៨០,០ លានម៉ែត្រគូប មានការកើនឡើង៩,៨%ធៀបនឹងឆ្នាំ ២០១៨។

⇨ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន ១ ៧៣០ រោងចក្រ កើនឡើង ១៣,២%ធៀបនឹងឆ្នាំ២០១៨។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម:**

| *ប្រភេទ* | *ចំនួន :២០១៩* | *ចំនួន:២០១៨* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១ ៧៣០ | ១ ៥២៨ | +១៣,២% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ២៦៩ | ១៧៨ | +៥១,១% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៦២ | ១១៦ | ៤៦,៦% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៧០ | ២០០ | ៦៥,០% |

## ➢ *រ៉ែនិងថាមពល:*

⇨ ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១១ ៤៨២,៧ GWh កើនឡើង ២១,១%។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ៤ ០១៧,៧ GWh ថយចុះ១៥,១% ធ្យូងថ្មចំនួន ៣ ៧៣៤,០ GWh កើនឡើង ២២,២% នាំចូលពីប្រទេសជិតខាងចំនួន ២ ៨៤៦,៨ GWh កើនឡើង ១១០,៥% និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតចំនួន៨៨៤,១ GWh កើនឡើង ១៦០,៧% ធៀបនឹងឆ្នាំ២០១៨។

⇨ ផលិតកម្មស៊ីម៉ង់ត៍ ក្នុងឆ្នាំ២០១៩ សម្រេចបានចំនួន ៧ ៨៩៦,៤ ពាន់តោន។

## ➢សំណង់ (ការអនុញ្ញាត):

▪ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១៩ មានចំនួន ២៣ ២៦៤,៦ ពាន់ម² មានការកើនឡើង៨៧,៩%បើគិតជាទឹកប្រាក់ស្មើនឹង ១១ ៤៣៨,៤លានដុល្លារមានការកើនឡើង៩៨,៧% ធៀបនឹងឆ្នាំ ២០១៨។

| *ប្រភេទសំណង់* | ពាន់ម² :២០១៩ | ពាន់ម² :២០១៨ | % ∆ |
|---|---|---|---|
| លំនៅឋាន | ១០ ៦២៦,៩ | ៥.១៨២,៨ | ១០៥,០% |
| ឧស្សាហកម្ម | ៣ ៦៩៧,៤ | ៨៨៤,៦ | ៣១៨,០% |
| ពាណិជ្ជកម្ម | ៧ ៣១៦,៨ | ៣ ៧០៤,០ | ៩៧,៥% |
| ទេសចរណ៍ | ១ ៤៥០,៩ | ២ ២៦០,៨ | -៣៥,៨% |
| សាធារណៈ | ១៣៩,២ | ១៥៤,២ | -៩,៧% |
| ផ្សេងៗ | ១២,៧ | ១៣,៤ | -៤,៨% |
| អនុញ្ញាតសរុប | ២៣ ២៦៤,៦ | ១២.៣៧៨,១ | ៨៧,៩% |

▪ ក្នុងការអនុញ្ញាតនេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (៤៥,៧%នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (៣១,៥% នៃផ្ទៃក្រឡាសរុប)។

## ➢ការចុះបញ្ជីនិងលុបចេញពីបញ្ជី

| *ប្រភេទ* | ២០១៩ (*ចំនួន*) | ២០១៨ (ចំនួន) | *%∆* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១១ ៣១៤ | ១២ ៤៤០ | -៩,១% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៤០ | ១៤៣ | -២,១% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១១ ១០៣ | ៦ ១០៩ | +៨១,៧% |

▪**ការងារ:**

| *ប្រភេទ* | ២០១៩ (នាក់) | ២០១៨ (នាក់) | %∆ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ (ទីភ្នាក់ងារជាតិមុខរបរ និងការងារ) | ១៨ ៦៥៦ | ១៦ ៥២៧ | +១២,៩% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ២១១ ៩៩៦ | ៤៨១ ៩៩៤ | -៥៦,០% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៤៣ ៩៥៦ | ១៣៩ ៨៤០ | +២,៩% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៦៨ ០៤០ | ៣៤២ ១៥៤ | -៨០,១% |

▪***វិនិយោគ:**គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. ក្នុងឆ្នាំ២០១៩*

| *ប្រភេទ* | *២០១៩* | *២០១៨* | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៩៣៩៧,៦ | ៦៤៥១,៥ | +៤៥,៧% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៧២,៥ | ៤៥៧,៧ | -៦២,៣% |
| វិស័យឧស្សាហកម្ម | ១៩៣៤,៣ | ១៥៤៨,៧ | +២៤,៩% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ១០១២,៣ | ៤៤២,១ | +១២៩,០% |
| វិស័យទេសចរណ៍ | ៦៣១១,១ | ១៦១២,៥ | +២៩១,៤% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៩៧៩,៧ | ២៨៣២,៦ | -៦៥,៤% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ៣១៥ | ២៥៥ | +២៣,៥% |
| **ចំនួនពលករ (ពាន់នាក់)** | ៣២៥,៦ | ២៣៧,៤ | +៣៧,២% |

▪***សេវាកម្មនិងទេសចរណ៍:***

➢**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប២កំពង់ផែ)មានចំនួន ១០ ៣៥៨,៥ ពាន់តោនថយចុះ០,៣% ធៀបនឹងឆ្នាំ២០១៨។ ក្នុងនោះ:

| *ប្រភេទ* | ២០១៩ (ពាន់តោន) | ២០១៨ (ពាន់តោន) | %∆ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ៣ ៨១០,៧ | ៣ ១៦២,០ | +២០,៥% |
| កំពង់ផែកំពង់សោម | ៦ ៥៤៧,៨ | ៧ ១៨៣,៧ | -៨,៩% |

➢**ការចុះបញ្ជី និងចរាចរណ៍**

**ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍**

| *ប្រភេទ* | ២០១៩ (ចំនួន) | ២០១៨ (ចំនួន) | %∆ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៥៤០,៦ | ៥០២,៧ | +៧,៥% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី (ពាន់គ្រឿង) | ១០៥,៥ | ៧៧,២ | +៣៦,៦% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៤ ១២១ | ៣ ៣៥២ | +២២,៨% |

➢**ប្រៃសណីយ៍និងទូរគមនាគមន៍**

| *ប្រភេទ* | ២០១៩ | ២០១៨ | %∆ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស (ពាន់កញ្ចប់) | ២៥៧,៤ | ២២៣,៨ | +១៥,០% |
| ក្នុងនោះទទួល | ៣០,៤ | ២៨,៣ | +៧,៤% |
| បញ្ញើក្រៅប្រទេស (ពាន់កញ្ចប់) | ១ ០៨៤,១ | ១ ១៩៨,៩ | -៩,៦% |
| ក្នុងនោះទទួល | ៦៣០,១ | ៦៤៤,៤ | -២,២% |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ២០១៩ | ២០១៨ | %∆ |
|---|---|---|---|
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៧ ១២៩,៥ | ២២ ២៧១,៥ | -២៣,១% |
| ក្នុងនោះហៅចូល | ៦ ១១៦,១ | ៦ ៦៩១,៣ | -៨,៦% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៦៤ ៨៧៧,៤ | ៨១ ៧០៧,៧ | -២០,៦% |
| ក្នុងនោះហៅចូល | ៦៤ ១៥៦,២ | ៨០ ៥៩៣,៤ | -២០,៤% |

### ➢អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ២០១៩ (ពាន់នាក់) | ២០១៨ (ពាន់នាក់) | %∆ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៧៦,២ | ២០៩,២ | -១៥,៨% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ២ ២០៥,៧ | - | - |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១២១,៧ | - | - |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១ ១១៥,៧ | ៦៣៦,៧ | +៧៥,២% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ១០ ២២៨,៩ | ៩ ៣៧៦,៤ | +៩,១% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ២ ០៣៨,៣ | ១ ៩៩៥,៥ | +២,១% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៦ ៦១០,៦ | ៦ ២០១,១ | +៦,៦% |
| ✓តាមផ្លូវអាកាស | ៤ ៤០៤,០ | ៤ ០៩៦,៩ | +៧,៥% |
| ✓ តាមផ្លូវគោក និងទឹក | ២ ២០៦,៦ | ២ ១០៤,២ | +៤,៩% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១៩ មានចំនួន ៧៩ ៨០៣,៩ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១៩ ៩៥១,០ លានដុល្លារ)កើនឡើង ១៧,៧% បើធៀបនឹងឆ្នាំ២០១៨ ក្នុងនោះ ៖

| មានការថយចុះ | មានការកើនឡើង |
|---|---|
| គ្រាក់ទ័រនិងគោយន្ត-១៩.៨% | ប្រេងសាំង +១៧,៤% |
| អង្ករ -៥,៥% | ប្រេងម៉ាស៊ូត +២៤,១% |
| ថ្នាំកសិកម្ម-៦២,១% | ប្រេងសាំងយន្តហោះ +១១,៥% |
| នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម-៨៩,១% | ប្រេងខ្មៅ+២៩,១% |
| សម្លៀកបំពាក់ -៨,០% | ឧស្ម័ន +២៦,១% |
| ស្ករស -០,៤% | ដែកសំណង់+៥៣,១% |
| ប្រេងឆា -០,៩% | ស៊ីម៉ង់ +៤៥,៨% |
| ប៊ីចេង -១០,៩% | រថយន្តទេសចរណ៍+៣២,៦% |
| | ស្រូវសាលី+២៥៩,២% |
| | ផ្លែឈើនិងបន្លែ +៥,០% |
| | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +០,៥% |

▪**ការនាំចេញ**ឆ្នាំ២០១៩មានចំនួន ៦០ ៤៨៤,៣ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១៥ ១២១,០លានដុល្លារ)ស្មើនឹង៧៥,៨%នៃការនាំចូល មានការកើនឡើង១៧,៤% ធៀបនឹងឆ្នាំ២០១៨ក្នុងនោះ ៖

| ទំនិញ | %∆ធៀបនឹង-២០១៨ | ទំនិញ | %∆ធៀបនឹង-២០១៨ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | −១០,៨% | ផលិតផលនេសាទ | −៣៦,៣% |
| វាយនភណ្ឌនិងស្បែកជើង | +១១,៦% | កៅស៊ូ | −០,៦% |
| អង្ករ | −០,៨% | | |

## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែធ្នូឆ្នាំ២០១៩ |
|---|---|---|
| ១ | ០២/១២/១៩<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមិទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤១ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ២ | ០៣/១២/១៩<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរសន្និបាតបូកសរុបការងារអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ ព្រមទាំងទិវាជនមានពិការភាពកម្ពុជាលើកទី២១ និងអន្តរជាតិលើកទី៣៧ ក្រោមប្រធានបទ "លុបបំបាត់ឧបសគ្គរាំងជនមានពិការភាព ដើម្បីសង្គមមួយប្រកបដោយបរិយាបន្ន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ៣ | ០៣/១២/១៩<br>ម៉ោង១៥:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/១២/១៩<br>ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកផ្លូវការនៃមហាសន្និបាតលើកទី៣៩ របស់សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ៥ | ០៥/១២/១៩<br>ម៉ោង០៧:២០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់សមណនិស្សិត និងនិស្សិត នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៦ | ១០/១២/១៩<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ានលើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ១១/១២/១៩<br>ម៉ោង០៧:២០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ កម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

| | | |
|---|---|---|
| ៨ | **១២/១២/១៩ ម៉ោង១៦:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ិន ទីរៈជាតិ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **១៦/១២/១៩ ម៉ោង០៧:២០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត សាលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ១០ | **១៧/១២/១៩ ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨ ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទចតុម្មុខ។ |
| ១១ | **១៨/១២/១៩ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត សាកលវិទ្យាល័យវេស្ទើន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ១២ | **១៩/១២/១៩ ម៉ោង១៥:៣០នាទី** | ទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ី សារី** ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រៃល្វា នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **២១/១២/១៩ ម៉ោង១៧:០០នាទី** | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបើកជាផ្លូវការពិធីបុណ្យសមុទ្រលើកទី៨ ជុំទី២ ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅបរិវេណពហុកីឡដ្ឋានខេត្តកំពត។ |
| ១៤ | **២២/១២/១៩ ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារបន្តរបស់គណៈចលនាមហាជន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ |
| ១៥ | **២៣/១២/១៩ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **លី គឹមសុខ** ឯកឧត្តម **ឆយ អូន** និងឯកឧត្តម **កែវ ទិចិត្រ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៤/១២/១៩ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៦/១២/១៩ ម៉ោង០៧:២០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែមករាឆ្នាំ២០២០ |
|---|---|---|
| ១ | ០៣/០១/២០ ម៉ោង១០:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៧/០១/២០ ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤១ ទិវាជ័យជម្នះ ៧ មករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីកាគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅសួនច្បារសាលមហោស្រពខេត្តតាកែវ។ |
| ៣ | ០៨/០១/២០ ម៉ោង០៨:៣០នាទី | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី (អគារថ្មីខាងត្បូង សាល៧-០៨ ជាន់ទី៧) ។ |
| ៤ | ១៤/០១/២០ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ៥ | ១៥/០១/២០ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ៦ | ២០/០១/២០ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំដើម្បីពិភាក្សាអំពីការបង់វិភាគទានជួយក្រុមការងារចុះមូលដ្ឋាន នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ២១/០១/២០ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ៨ | ២២/០១/២០ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ៩ | ២៨/០១/២០ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ១០ | ៣១/០១/២០ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែកុម្ភៈឆ្នាំ២០២០ |
|---|---|---|
| ១ | ០១/០២/២០ ពេញមួយថ្ងៃ | ចូលរួមសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤២ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ |
| ២ | ០២/០២/២០ ពេញមួយថ្ងៃ | ចូលរួមសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤២ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ |

| | | |
|---|---|---|
| ៣ | ០៤/០២/២០<br>**ម៉ោង០៩:៣០នាទី** | ប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **នរ៉ាណារ៉ុទ្ធិ អានន្ទជាយ៉ាត** និងឯកឧត្តម **លី គឹមសុខ** នៅបន្ទប់ឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៥/០២/២០<br>**ម៉ោង០៩:០០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>៣- គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ២៦៥ មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍបណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ពីរោងចក្រអគ្គីសនីធ្យូងថ្មខេត្តឧត្តរមានជ័យ អនុស្ថានីយសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ៧០០ មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងអនុវត្តបន្តទៀត<br>៤- បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៦/០២/២០<br>**ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>៣- គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ២៦៥ មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍបណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ពីរោងចក្រអគ្គីសនីធ្យូងថ្មខេត្តឧត្តរមានជ័យ អនុស្ថានីយសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ៧០០ មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងអនុវត្តបន្តទៀត<br>៤- បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៧/០២/២០<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

| | | |
|---|---|---|
| | | ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>៣- គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ២៦៥ មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍបណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ពីរោងចក្រអគ្គីសនីធ្យូងថ្មខេត្តឧត្តរមានជ័យ អនុស្ថានីយសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ៧០០ មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងអនុវត្តបន្តទៀត<br>៤- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ ៖<br>៤.១- សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជា-ណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>៤.២- សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>៤.៣- ពិធីសារទីមួយ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន<br>៤.៤- ពិធីសារទីពីរ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន<br>៤.៥- ពិធីសារទីបី ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៧ | **១១/០២/២០<br>ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានគម្រោងធ្វើឱ្យប្រសើរឡើងវិញកំណាត់ផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ២២ សរុបប្រវែង៧២,១៧គ.ម ចាប់ពីរង្វង់មូលតាខ្មៅ-អូរចំបក់ និងទៅដល់អង្គតាសោម ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅក្នុងបរិវេនភូមិកណ្តាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ |
| ៨ | **១៣/០២/២០<br>ម៉ោង០៨:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **១៤/០២/២០<br>ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងកិច្ចប្រជុំ ផ្សព្វផ្សាយលទ្ធផលនៃសន្និបាតគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាលើកទី៤២ អាណត្តិទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **១៥/០២/២០<br>ម៉ោង០៨:០០នាទី** | ចូលរួមក្នុងកិច្ចប្រជុំ ផ្សព្វផ្សាយលទ្ធផលនៃសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤២ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីកាគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |

| | | |
|---|---|---|
| ១១ | **១៧/០២/២០ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ១២ | **១៨/០២/២០ ម៉ោង០៧:២០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូននិស្សិតអធិការអប់រំ និងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) គ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៣ | **២០/០២/២០ ម៉ោង០៩:០០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំក្រុមការងារសិក្សាស្រាវជ្រាវលើសេដ្ឋកិច្ច-សង្គម ដែលផ្តោតទៅលើជីវភាពរស់នៅជាក់ស្តែងរបស់ប្រជាពលរដ្ឋ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២២/០២/២០ ម៉ោង០៨:០០នាទី** | ចូលរួមជាអធិបតី ក្នុងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលនៃសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤២ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា នៅស្នាក់ការសហភាពសហព័ន្ធយុវជនស្រុកព្រៃកប្បាស។ |
| ១៥ | **២៥/០២/២០ ម៉ោង០៧:២០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រជូននិស្សិតមន្ត្រីជាន់ខ្ពស់ជំនាន់ទី៨ សិស្សមន្ត្រីក្រមការ និងវិញ្ញាបនបត្រជូនកម្មសិក្សាការីជាន់ខ្ពស់ មន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីមធ្យម និងមន្ត្រីក្រមការឆ្នាំ២០១៨ និងសិក្ខាកាមវគ្គថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងជាស្ត្រី ព្រមទាំងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២០ នៃសាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៦ | **២៦/០២/២០ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៧/០២/២០ ម៉ោង១០:០០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីបិទសន្និបាតបូកសរុបការងារទេសចរណ៍ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តឆ្នាំ២០២០ និងពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី៨ ឆ្នាំ២០២០ ក្រោមប្រធានបទ "ទីក្រុងស្អាត ទីក្រុងដែលមានវិថីម្ហូបអាហារស្អាត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខារ៉ែស៊ីដង់ភ្នំពេញ។ |
| ១៨ | **២៨/០២/២០ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំបន្តគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **២៨/០២/២០ ម៉ោង១១:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## ពន្យល់ពាក្យ

ទោស ន. (បា) : គឺជាការប្រទូស្ត កំហឹង សម្អប់ កំហុស មានទោសធ្ងន់។ ពាក្យទំនៀមបុរាណបានចែងថា៖ " ស្នាបាក់កុំចាក់ច្បោស មនុស្សមានទោសកុំយកខ្លួនបៀត " ពាក្យនេះ បើនិយាយចំពោះកំហឹងតែងអានឬសរសេរថាទោសៈ : មនុស្សមានទោសៈ ចិត្តប្រកបដោយទោសៈ។

១- នានាភាពនៃទោស៖

- ទោសការណ៍ ន. - ហេតុ ដំណើរ ដែលបណ្ដាលឲ្យកើតទោស ឬដែលប្រកបដោយទោស។
- ទោសចរិត ន. ឬ គុ. - ចរិតប្រកបដោយទោស បុគ្គលដែលក្រាស់ដោយទោស។
- ទោសចិត្ត ន. - ចិត្តប្រកបដោយទោស ចិត្តដែលបណ្ដាលជាទោស។
- ទោសសញ្ញូ ន. - អ្នកស្គាល់ទោស អ្នកស្គាល់ខុសត្រូវ(អ្នកប្រាជ្ញ)។
- ទោសពៃរ៍ ន. - ទោសនិងពៀរ ទោសជាពៀរ។ ឧទាហរណ៍ៈ អ្នកចេះតែធ្វើការនុំះទៅចុះ ខ្ញុំអត់ប្រកាន់ទោសពៃរ៍អ្វីទេ។
- ទោសមូល ន. - ឫសអកុសលដែលបណ្ដាលអំពីទោស ទោសជាឫសនៃអកុសល។
- ទោសាគតិ ន. - សេចក្ដីលម្អៀងព្រោះទោស ដំណើរលម្អៀងដោយសម្អប់។
- ទោសានុទោស ន. - ទោសតូចនិងទោសធំ ទោសកំហុសគ្រប់យ៉ាង។
- ទោសោ ន. - គឺកើតកំហឹង ឧទាហរណ៍ៈ កើតទោសោ។
- ទោសការងារសហាគមន៍ ក.ន. - ( Peine de travail d'intérêt général ) គឺជាទោសជំនួសមួយប្រភេទដែលតម្រូវឲ្យទណ្ឌិតបំពេញការងារក្នុងចិរវេលាចន្លោះពី៣០ម៉ោងទៅ២០០ម៉ោង ដោយគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀត ដល់សហាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។
- ទោសជំនួស ក.ន. - ( Peine de substitution ) គឺជាទោសការងារសហាគមន៍ ឬការស្ដីបន្ទោសដែលត្រូវបានកំណត់ ជាជំនួសទោសដាក់ពន្ធនាគារ។
- ទោសសេពសុរា ក.ន. - គឺជាកំហុសបណ្ដាលមកពីការផឹកស្រាមាន៦យ៉ាង៖

| | | |
|---|---|---|
| ទោសទី១ | > | វិនាសទ្រព្យ |
| ទោសទី២ | > | ឈ្លោះប្រកែក |
| ទោសទី៣ | > | ឈឺថ្កាត់ |
| ទោសទី៤ | > | និន្ទាឈ្នានីស |
| ទោសទី៥ | > | បញ្ចេញកេរ្តិ៍ខ្មាស់ |
| ទោសទី៦ | > | ខ្សោយបញ្ញា |

-ទោសលេងល្បែងស៊ីសងក.ន.-គឺជាកំហឹងឬកំហុសបណ្ដាលមកពីការលេងល្បែងភ្នាល់មាន៥យ៉ាង៖

| | | |
|---|---|---|
| ទោសទី១ | > | ក្ដៅក្រហាយចងគំនុំនឹងអ្នកឈ្នះនៅពេលខ្លួនចាញ់ |
| ទោសទី២ | > | ស្ដាយទ្រព្យដែលវិនាសទៅ |
| ទោសទី៣ | > | ឃើញទ្រព្យវិនាសហិនហោច |
| ទោសទី៤ | > | ត្រូវគេមើលងាយ |
| ទោសទី៥ | > | អភ័ព្វនឹងរកគូស្រករ |

# ចូលឆ្នាំថ្មី

ចូលឆ្នាំថ្មី ក.ន. : គឺជាបុណ្យប្រពៃណីដ៏សំខាន់មួយរបស់ប្រជាជនខ្មែរដែលមានអាយុកាលយូរលង់ណាស់មកហើយ។ ខ្មែរនិយមចូលឆ្នាំថ្មីនៅខែចែត្រ។ តាមពិតខ្មែរចូលឆ្នាំជាពីរលើក។

លើកទី១ : គិតតាមដំណើរព្រះច័ន្ទ និងការផ្លាស់ឈ្មោះសត្វប្រចាំឆ្នាំ។ ឈ្មោះសត្វប្រចាំឆ្នាំទាំង១២មានៈ

| | | | |
|---|---|---|---|
| ១- ឆ្នាំជូត នាមសត្វ | | កណ្តុរ | (បា. មូសិក សំ. មូសិក) |
| ២- ឆ្នាំឆ្លូវ | - | គោ | (បា. ឧសភ សំ. ឫសភ) |
| ៣- ឆ្នាំខាល | - | ខ្លា | (បា. ព្យគ្ឃ សំ. វ្យាឃ្រ) |
| ៤- ឆ្នាំថោះ | - | ទន្សាយ | (បា. សស សំ. សស) |
| ៥- ឆ្នាំរោង | - | នាគ ឬពស់ធំ | (បា. នាគ សំ. នាគ) |
| ៦- ឆ្នាំម្សាញ់ | - | ពស់ ឬពស់តូច | (បា. សប្ប សំ. សបី) |
| ៧- ឆ្នាំមមី | - | សេះ | (បា. អស្ស សំ. អស្វ) |
| ៨- ឆ្នាំមមែ | - | ពពែ | (បា. ឯឡក សំ. ឯឡក) |
| ៩- ឆ្នាំវក | - | ស្វា | (បា. មក្កដ សំ. បកិដ) |
| ១០- ឆ្នាំរកា | - | មាន់ | (បា. កុក្កុរ សំ. កុក្កុត) |
| ១១- ឆ្នាំច | - | ឆ្កែ | (បា. សុនខ សំ. សុនខ) |
| ១២- ឆ្នាំកុរ | - | ជ្រូក | (បា. សូករ សំ. សូករ) |

ការចូលឆ្នាំត្រូវកំណត់នៅក្នុងថ្ងៃទី១ នៃខែចែត្រ។

លើកទី២ : គិតតាមដំណើរព្រះអាទិត្យ ហើយដែលគេសម្គាល់ថាចូលឆ្នាំជាសាមញ្ញ ឬរបស់ពលរដ្ឋ។ ការចូលឆ្នាំនេះមិនសូវទៀងទាត់ទេ ជួនកាលត្រូវលើកថ្ងៃទី១៣ ជួនកាលត្រូវលើថ្ងៃទី១៤ ខែមេសា ប៉ុន្តែច្រើនត្រូវលើថ្ងៃទី១៣ជារឿយៗជាង។នៅចន្លោះពេលពីថ្ងៃចូលឆ្នាំលើកទី១ទៅថ្ងៃចូលឆ្នាំលើកទី២តែងតែមានពេលយូរឬឆាប់តាមកាលៈទេសៈ។

សព្វថ្ងៃនេះ អ្នកស្រុកនិយមធ្វើបុណ្យចូលឆ្នាំជាឱឡារិក តែនៅពេលចូលឆ្នាំគិតតាមដំណើរព្រះអាទិត្យនេះហើយ បុណ្យនេះត្រូវធ្វើចំនួន៣ឬ៤ថ្ងៃ តាមការកំណត់របស់ក្រុមហោរាសាស្ត្រ។ ប្រទេសខ្មែរយើងពីដើមគឺចាប់ពីត្រឹមសម័យក្រុងនគរធំឡើងទៅប្រើច័ន្ទគតិជាសំខាន់ទើបបានដាក់លេខរៀងខែមិគសិរជាខែទី១ហើយចូលឆ្នាំក្នុងខែនេះ តាមដែលមានកំណត់របស់បេសកជនចិនឈ្មោះ ជាវ តាគួន ដែលបានមកស្រុកខ្មែរក្នុងគ.ស. ១២៩៥ ដែលបានកត់ត្រាពីប្រវត្តិការណ៍ស្រុកខ្មែរ មានសេចក្តីថា "ខ្មែរចូលឆ្នាំក្នុងខែទី១ ត្រូវនឹងខែទី១០របស់ចិន"។ ខែដែលថាត្រូវនឹងខែទី១០របស់ចិន គិតទៅឃើញត្រូវនឹងខែកត្តិក(ទី១២)របស់ខ្មែរ បើថាត្រូវនឹងខែទី១១របស់ចិននោះត្រូវចំជាង តែសេចក្តីពិតក៏មិនខុស ព្រោះពីដើមគេរាប់ពីថ្ងៃ១រោជខែកត្តិកដល់ពេញបូណ៌មីខែមិគសិរ។ លុះពេលក្រោយមក ប្រមាណពីពេលក្រោយដែលបានផ្តើមចុល្លសករាជមក ទើបត្រឡប់ប្រើសុរិយគតិ ហើយកំណត់ចូលឆ្នាំខែចែត្រ(ទី៥) ហើយកំណត់យកព្រះអាទិត្យចូលកាន់មេសារាសីដែលជាសាមញ្ញសង្រ្កាន្តគឺព្រះអាទិត្យដើរត្រង់ពីលើក្បាលជាសង្រ្កាន្តវិញមិនយកតាមអាយន្តសង្រ្កាន្តដូចមុន។ កាលកំណត់តាមសាមញ្ញសង្រ្កាន (សុរិយាគតិ) ដូចនេះហើយថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី១៣ នៃខែមេសា។ ឯកំណត់ចូលឆ្នាំតាមអាយន្តសង្រ្កាន្ត (ច័ន្ទគតិ) នៅថ្ងៃចូលឆ្នាំមិនបានទៀងនឹងជាថ្ងៃណាមួយ ឆ្នាំនេះចូលក្នុងថ្ងៃនេះ ឆ្នាំក្រោយចូលក្នុងថ្ងៃឯណោះទៅវិញ មានខ្នើតមានរនោចមិនត្រង់គ្នាគ្រាន់តែមានកំណត់ថា ទុកថាសង្រ្កាន្តនឹងមានក្នុងរវាង១ខែ គឺមុនថ្ងៃ៤កើត ខែចែត្រ និងមិនហួសថ្ងៃ៤កើត ខែពិសាខទេ ដូចនេះឃើញថា

សង្ក្រាន្តឆ្នាំខ្លះធ្លាក់ទៅក្នុងខែពិសាខក៏មាន។ ដោយហេតុនេះ ការកំណត់ចូលឆ្នាំថ្មីរបស់ខ្មែរយើង ទើបមានជាពីររយៈគឺនៅថ្ងៃ១កើត ខែចែត្រ រាប់ជាឆ្នាំថ្មីហើយ ព្រោះផ្លាស់ឈ្មោះឆ្នាំតាមនក្ខត្តឫក្ស គឺ ជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែ វក រកា ច កុរ តែនៅមិនទាន់ដល់កម្រិតផ្លាស់ស័ក ឬសករាជនៅឡើយ លុះត្រាតែព្រះអាទិត្យគោចរចូលកាន់រាសីមេសៈកាលណាទើបផ្លាស់សករាជថ្មីក្នុងថ្ងៃនោះ គឺថ្ងៃដែលយើងហៅថា ថ្ងៃឡើងស័ក។ ក្នុងរវាងដែលមិនទាន់ឡើងសករាជ ត្រូវប្រើឬត្រូវរាប់ជាឆ្នាំថ្មីហើយ តែសករាជត្រូវនៅក្នុងឆ្នាំចាស់នៅឡើយ។ តាមឯកសារលោក ជាវ តា គួន «Tcheou Ta Kouan» បញ្ជាក់ពីការដែលសម័យអង្គរបានរៀបចំពិធីចូលឆ្នាំរបស់ខ្លួនមានរបៀបដូចជា៖

- គេយកខែទី១០របស់ចិនធ្វើជាខែទី១ ហើយខែនេះមានឈ្មោះថា Kia To ( Katik – Sangskrit Kattika ) គឺកត្តិក
- រៀបវេទិកានៅមុខវាំង អាចដាក់មនុស្សជាង១,០០០នាក់
- មានតុបតែងដោយគោមនិងភ្ញីផ្កា
- មានសសរធ្វើស្តូប ( ៣ ៤ ៥ ឬ ៦ ) មានចងកាំជ្រួចនិងផាវនៅខាងចុង
- កាំជ្រួចនិងផាវ គេដុតនៅពេលយប់មានស្តេចជាអធិបតី
- មន្ត្រីមានកាន់ទៀននិងស្លា
- អញ្ជើញទូតឲ្យចូលរួមពិធី
- បុណ្យនេះមានរយៈពេល១៥ថ្ងៃ

ឯបុណ្យប្រចាំខែមាន៖

- ខែទី៤ « ចោលឈូង » ( on jette la balle )
- ខែទី៥ « ស្រង់ព្រះ »
- ខែទី៦ « អុំទូក »
- ខែទី៧ « ដុតស្រូវបូជាចំពោះព្រះពុទ្ធ »
- ខែទី៨ « រាំរែក » ( Ngai-lan )
- ខែទី៩ « ក្បួនដង្ហែ » ( Ya lie ) គេប្រជុំមនុស្សមកចូលទីក្រុង ហើយហាត់ក្បួនដើរដង្ហែកាត់មុខវាំង

មានល្បែងប្រជល់ជ្រូក ប្រជល់ដំរី មួយផ្នែកទៀតមានក្បួនតារាសាស្ត្រ និងហោរាសាស្ត្រសម្រាប់គន់គូររកពេលសូរ្យគ្រាសនិងចន្ទគ្រាសពិសេសគឺជនជាតិនៅតំបន់នោះឬនគរនោះមានឈ្មោះដែលដាក់ផ្ទាល់របស់ខ្លួនបូកនឹងថ្ងៃកំណើត។

ឯឈ្មោះសត្វប្រចាំឆ្នាំទាំង១២ត្រូវគ្នានឹងចិនតែឈ្មោះហៅសម្គាល់ឆ្នាំទាំងនោះខុសគ្នាពីចិនដូចជា៖

| | | |
|---|---|---|
| សេះ | ហៅ | « pou - sai » |
| មាន់ | - | « man » |
| ជ្រូក | - | « Tche - lou » |
| គោ | - | « Ko » |

ឯពិធីបុណ្យដែលជាប់រហូតមកដល់សព្វថ្ងៃមាន៣ឬ៤ថ្ងៃ រួមទាំងចូលឆ្នាំតាមបែបចន្ទគតិ និងសុរិយគតិ គឺចាប់ពីថ្ងៃទី១៣ឬ១៤មេសា ក្នុងចន្លោះខាងច័ន្ទគតិ គឺមិនមុនថ្ងៃ៤កើតខែចែត្រ និងមិនហួសថ្ងៃ៤កើតខែពិសាខ។ ដូចនេះសង្ក្រាន្តកំណត់ពីដំណាច់ឆ្នាំចាស់មកចំណូលឆ្នាំថ្មី គេឲ្យឈ្មោះថាថ្ងៃសង្ក្រាន្ត៖

- ថ្ងៃដំបូង ហៅថា ថ្ងៃមហាសង្ក្រាន្ត ឬថ្ងៃចូលឆ្នាំ
- ថ្ងៃទី២ ហៅថា ថ្ងៃវនៃបត គឺជាថ្ងៃខ្វាក់ ឬថ្ងៃចន្លោះ ជាថ្ងៃធម្មតាមិនអាចរាប់ចូលក្នុងពិធី មិនរាប់យកជាបានការ

- ថ្ងៃទី៣ ហៅថា ថ្ងៃឡើងស័កគឺជាថ្ងៃដែលផ្លាស់សករាជ ហើយចូលស្រឡះទៅក្នុងឆ្នាំថ្មី

តាមទំនៀមថា :

- ថ្ងៃសង្ក្រាន្ត និង ថ្ងៃវនបត ជាថ្ងៃមិនល្អទាំងអស់
- ថ្ងៃឡើងស័ក ជាស្តេចថ្ងៃ ជាថ្ងៃល្អ

បុណ្យសំខាន់ៗក្នុងពេលចូលឆ្នាំមាន៖

- ពិធីពូនភ្នំខ្សាច់
- ពិធីត្រិស្តសង្ក្រាន្ត

១. ពិធីពូនភ្នំខ្សាច់ : បុណ្យនេះគេអាចចាប់ធ្វើបានតាំងពីដើមខែចែត្ររហូតមក។ តែតាមធម្មតាគេច្រើនតែពូនភ្នំខ្សាច់នៅទីវត្តពីល្ងាចមុនថ្ងៃចូលបុណ្យ។អ្នកណាដែលមិនបានមកជួបក្នុងការស្ថាបនាភ្នំនោះទេ នៅពេលជាបន្ទាប់មកអាចយកដីខ្សាច់២-៣ក្តាប់ទៅបាចលើដីនោះក៏បាន។


ដែនទី ពិធីពូនភ្នំខ្សាច់

ព្រឹកឡើងពួកឧបាសក-សិកានាំគ្នាវេភត្តប្រគេនព្រះសង្ឃ រួចទើបនាំគ្នាដើរហែជាក្បួនប្រទក្សិណភ្នំនោះ៣ជុំ។រួចហើយអាចារ្យប្រកាសសុំសេចក្តីសុខចម្រើនចែកជូនទាយកទាយិកាគ្រប់ៗគ្នាហើយគេនាំគ្នាចូលទៅដោតធូបទៀនទង់ក្រដាសពណ៌នៅជើងភ្នំខ្សាច់ថែមទាំងប្រោះព្រំដោយទឹកអប់និងទឹកម្សៅរមៀត។

ប្រភេទបុណ្យមានជាបែបឯកជន(គ្រួសារ)និងបែបជាសាធារណៈគេអាចសាងភ្នំខ្សាច់នៅតាមគ្រួសារក៏បាន នៅក្នុងភូមិឋានក៏បាន នៅតាមទីអារាមក៏បាន ឬទីប្រជុំធំៗតំណាងជាតិទាំងមូល។ សណ្ឋាននៅតំបន់ខ្លះគេរចនាភ្នំខ្សាច់ដូចជាចេតិយ។ កាលណាគេធ្វើសម្រាប់គ្រួសារគេធ្វើដាក់លើតុ។ នៅតំបន់ខ្លះគេធ្វើនៅជិតដើមពោធិ៍ព្រោះគេយល់ថាព្រះពុទ្ធបានសម្រេចសព្វញ្ញុតញ្ញាណនៅក្រោមដើមពោធិ៍។ខ្លះទៀតគេពុំយកដីខ្សាច់មកធ្វើជាភ្នំទេគេយកស្រូវអង្ករឬនំមកធ្វើជាភ្នំ។តំណាងឬនិមិត្តរូបភ្នំខ្សាច់ដែលគេធ្វើឡើងដើម្បីជាតំណាងមហាបព៌តនៃលោកធាតុប្រចាំប្រទេសឥណ្ឌាគឺភ្នំខ្សាច់កណ្តាលតំណាងភ្នំសុមេរុរាជដែលទុកជាស្នូលឬជាគោលនៃពិភពលោក ឯភ្នំខ្សាច់តូចគ្រប់ទិសតំណាងសត្តបរិភណ្ឌដែលព័ទ្ធជុំវិញភ្នំសុមេរុរាជ។

មិតអ្នកប្រាជ្ញថា : ភ្នំកណ្តាលតំណាងព្រះចូឡាមណីចេតិយ ដែលតំកល់ព្រះកេសាព្រះពុទ្ធ កាលចាកជីវភាពក្សត្រទៅបួស។

ជំនឿប្រជារាស្ត្រថា : គ្រាប់ដីខ្សាច់១គ្រាប់ៗ អាចផ្តល់អានិសង្សដល់អ្នកធ្វើភ្នំនោះ ឲ្យបានរួចកម្មពៀរ។

ភ្នំខ្សាច់នោះមានរាជវត្តិព័ទ្ធជុំវិញ - មានទ្វារចេញទៅរកទិសទាំងបួន។

នៅខាងក្រៅរាជវត្តិមានរានទេព្តាគ្រប់ទិសទីទាំងបួនសម្រាប់បូជាចំពោះទេវតា។

គេសង់រោងមួយទៀតនៅទិសខាងកើត សម្រាប់បូជាដល់យមរាជ។

នៅក្រុងភ្នំពេញមានធ្វើពិធីនេះនៅវត្តភ្នំដូនពេញឯវត្តព្រះកែវមរកតក៏មានធ្វើពិធីនេះសម្រាប់រាជវង្សស្តេច។

ពិធីខាងរាស្ត្រ : ដូចបានរៀបរាប់នៅទំព័រខាងដើមរួចមកហើយគឺមាន៖

- ការវេរភត្តចំពោះព្រះសង្ឃ
- ប្រទក្សិណា៣ជុំ
- ប្រកាសសុំពរសុខចម្រើន
- ប្រគេនទេយ្យទាន
- ឯភ្នំដូនពេញ មានធ្វើពិធីបង្សុកូលនៅក្បែរចេតិយធំ ដើម្បីបញ្ជូនផលានិសង្សដល់អ្នកស្លាប់...

ជាទូទៅនៅពេលរសៀលអ្នកស្រុកនិយមធ្វើពិធីនិមន្តព្រះសង្ឃស្រង់ទឹក នៅកន្លែងខ្លះទៀតនិយមធ្វើកិច្ចស្រង់ព្រះពុទ្ធរូប ហើយឧទ្ទិសសុំឲ្យមានភ្លៀងបរិបូណ៌។ ល្បែងក្នុងរយៈពេលចូលឆ្នាំនោះ អ្នកស្រុកនាំគ្នាលេងល្បែងតាមចំណូលចិត្តស្រីប្រុស ដូចជា៖

- បោះឈូងច្រៀង
- ល្បែងអង្គញ់
- រាំត្រុដិនៅតំបន់សៀមរាប បាត់ដំបង ដើម្បីប្រមូលបច្ច័យទុកជាសម្បត្តិវត្ត
- អុំទូកក្នុងព្រះវិហារ (នៅកណ្តាលវត្ត) ឧបកិច្ចឲ្យក្រពើស្លូត
- បញ្ជាន់រូបនៃខ្មោចបិសាច ដែលនៅដើមឈើក្បែរវត្តដើម្បីសុំសេចក្តីសុខ-ចម្រើន
- មួយផ្នែកទៀត គេនិយមចូលចិត្តធ្វើទេសចរណ៍ទៅទស្សនាតំបន់នានា ដែលមានបុរាណវត្ថុបូជនីយកិច្ច ដើម្បីធ្វើសក្ការៈបូជាចំពោះវត្ថុសក្តិសិទ្ធិទាំងនោះ។

២.ពិធីត្រិស្តសង្ក្រាន្តចូលឆ្នាំ សង្ក្រាន្តមកពីពាក្យសំស្ក្រឹតថា "សង្ក្រាន្តិ" ប្រែថា "ដំណើរ" គឺនៅថ្ងៃនេះហើយ ដែលព្រះអាទិត្យចរចូលមកកាន់រាសីថ្មី។

ឯការចាប់បដិសន្ធិនៃរាសី(ផ្កាយ)ទាំងប្រាំពីរប្រចាំថ្ងៃក្នុងសប្តាហ៍មានរឿងតំណាលបុរាណមួយឈ្មោះសង្ក្រាន្តសូត្រ ដែលនិយាយអំពីក្នុងអតីតកាលមានកបិលមហាព្រហ្ម បានមកចោទប្រស្នា ៣ខ ៖

ខ១. វេលាព្រឹក សិរីស្កិតនៅត្រង់ណា?

ខ២. វេលាថ្ងៃត្រង់ សិរីស្កិតនៅត្រង់ណា?

ខ៣. វេលាល្ងាច សិរីស្កិតនៅត្រង់ណា?

ចោទចំពោះធម្មបាល ដែលជាអ្នកចេះភាសាសត្វ។ ហើយដាក់កម្រិតថា បើដោះប្រស្នាមិនរួចនឹងកាត់ក្បាលបូជា តែបើដោះរួចវិញកបិលមហាព្រហ្មនឹងកាត់ក្បាលព្រះអង្គបូជាចំពោះធម្មបាលវិញ។ ធម្មបាលអស់សង្ឃឹម តែដោយបានឮពាក្យសាសងរវាងសត្វឥន្ទ្រី ធម្មបាលក៏បានដោះប្រស្នានោះដោយថាតាមសត្វគឺ៖

១. វេលាព្រឹកសិរីស្កិតនៅត្រង់មុខ ទើបគេលាងមុខ

២. វេលាថ្ងៃត្រង់សិរីស្កិតនៅត្រង់ទ្រូង ទើបគេលាបទ្រូង

៣. វេលាល្ងាចសិរីស្កិតនៅត្រង់ជើង ទើបគេលាងជើង

ធម្មបាលដោះរួច កបិលមហាព្រហ្មសុខចិត្តកាត់ក្បាលបូជាធម្មបាល តែដោយគិតថាបើដាក់ក្បាល៖

- លើផែនដី នឹងកើតជាភ្លើងឆេះលោហធាតុ
- បោះលើអាកាស នឹងរាំងភ្លៀង
- ចោលក្នុងសមុទ្រ នឹងរីងសមុទ្រ

ទើបលោកចាត់កូនស្រីទាំង៧ឲ្យទទួលក្បាល៖

- ដំបូងកូនច្បង ឈ្មោះនាង ទុង្សា (ទី១) ប្រចាំថ្ងៃអាទិត្យ
- បន្ទាប់មក - គោរាគ (ទី២) - ច័ន្ទ
- - រាក្សសា(ទី៣) - អង្គារ
- - មណ្ឌា (ទី៤) - ពុធ
- - កិរិណី (ទី៥) - ព្រហស្បតិ៍
- - កិមិរា (ទី៦) - សុក្រ
- - មហោទរា(ទី៧) - សៅរ៍

ឲ្យយកពានមួយមកចាំទទួលក្បាលទៅរក្សាទុកឯភ្នំកៃលាសហើយផ្លាស់វេនគ្នារក្សាមួយឆ្នាំម្នាក់ដោយមុននឹងយកទៅហែប្រទក្សិណភ្នំព្រះសុមេរុចំនួន៦០នាទី ទើបយកទៅទុកឯភ្នំព្រះកៃលាសក្នុងគុហាគន្ធមាលា។

បើសង្ក្រាន្តត្រូវលើថ្ងៃណាត្រូវធីតាប្រចាំថ្ងៃនោះជិះម្រឹគទៅនាំក្បាលឱពុកចេញពីភ្នំកៃលាសដង្ហែជុំវិញភ្នំព្រះសុមេរុ រួចយកទៅទុកនៅកន្លែងដើមវិញ។

មហាសង្ក្រាន្តក៏ចេញប្រកាសប្រាប់នូវគ្រោះកាចគ្រោះជាក្នុងឆ្នាំនីមួយៗ។

ឈ្មោះទេពធីតាមហាសង្ក្រាន្តនិងគ្រឿងអាភរណៈ ៖

១. បើសង្ក្រាន្តថ្ងៃអាទិត្យ នាង ទុង្សា សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទម្ពរ អាវុធស្ដាំច័ក្រ ឆ្វេងស័ង្ខ ពាហនៈគ្រុឌ
២. បើថ្ងៃច័ន្ទ នាង គោរាគ សៀតផ្កាអង្គារបុស្ស គ្រឿងប្រដាប់មុក្តា ភក្សាហារប្រេង អាវុធស្ដាំព្រះខ័ន ឆ្វេងឈើច្រត់ ពាហនៈខ្លា
៣. បើថ្ងៃអង្គារ នាង រាក្សសា សៀតផ្កាឈូក គ្រឿងប្រដាប់មោរា ភក្សាហារលោហិត អាវុធស្ដាំត្រីសូល៍ ឆ្វេងធ្នូ ពាហនៈអស្សតរ
៤. បើថ្ងៃពុធ នាង មណ្ឌា សៀតផ្កាចំប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះសិប្ប អាវុធស្ដាំម្ជុល ឆ្វេងឈើច្រត់ ពាហនៈលា
៥. បើថ្ងៃព្រហស្បតិ៍ នាង កិរិណី សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែក ល្ង អាវុធស្ដាំកង្វេ ឆ្វេងកាំភ្លើង ពាហនៈដំរី
៦. បើថ្ងៃសុក្រ នាង កិមិរា សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្សរាគ័ម ភក្សាហារចេកណាំវ៉ា អាវុធស្ដាំព្រះខ័ន ឆ្វេងពិណ ពាហនៈក្របី
៧.បើថ្ងៃសៅរ៍ នាង មហោទរា សៀតផ្កាត្រកៀត គ្រឿងប្រដាប់និលរតន៍ ភក្សាហារសាច់ទ្រាយ អាវុធស្ដាំច័ក្រ ឆ្វេងត្រីសូល៍ ពាហនៈក្ងោក

ក្នុងថ្ងៃសង្ក្រាន្តច្រើនតែធ្វើក្នុងវាំងឯរាស្ត្រទូទៅពុំឃើញមានរបៀបចំធំដុំអ្វីជាអធិកអធមដូចក្នុងវាំងទេ៖

- ស្ដេចចេញថ្វាយបង្គំទេវតាថ្មី
- ស្ដេចស្រង់ឧទកធារា
- ស្ដេចយាងស្រង់ព្រះបញ្ចក្សេត្រ៖
    ១. ព្រះឥសូរ
    ២. ព្រះនារាយណ៍
    ៣. ព្រះពលទេព
    ៤. ព្រះគណេស
    ៥. ព្រះនាងឱមា

ថ្ងៃទីបី គឺថ្ងៃឡើងស័ក គឺថ្ងៃដែលផ្លាស់សករាជ ហើយចូលស្រឡះទៅក្នុងឆ្នាំថ្មី។ នៅវាំងមានពិធី៖

- បង្សុកូល
- ផឹកទឹកពិភទ្ទសច្ចា
- ប្រោះព្រំ ចតុរង្គសេនា : (១.សេនាដំរី ២.សេនាសេះ ៣.សេនារថ ៤.សេនាថ្មើរជើង)
-លេងល្បែងប្រណាំងដំរី
-លេងល្បែងប្រណាំងសេះ
-ប្រកួតចំបាប់និងប្រដាល់

ពិធីដែលស្តេចតែងប្រារព្ធ ធ្វើនៅឱកាសបុណ្យចូលឆ្នាំថ្មីនោះ មានទៅតាមថ្ងៃ៖

- ថ្ងៃទី១ ពិធីទទួលទេវតាថ្មី ការសាងវាលុកចេតិយ និងចម្រើនព្រះបរិត្ត
- ថ្ងៃទី២ វេលាព្រឹកវេរភត្តប្រគេនព្រះសង្ឃ វេលាល្ងាចនិមន្តព្រះសង្ឃ ស្រង់ទឹក ទេសនា សង្គាយនាឆ្លងបុណ្យ
- ថ្ងៃទី៣ ពិធីស្រង់ទឹកស្តេច

ស្តេចទទួលទឹកទៀនជ័យមង្គល

រណ្តាប់ទទួលទេវតា មានរៀបជារានទេវតា៧ថ្នាក់ និងគ្រឿងពលិការមានភ្លេងពិណពាទ្យ១វង់៖

- បាយសីធំ ១ គូ
- ស្លាធម៌ ១ គូ
- ទឹកអប់ ១ គូ
- ទៀន ៥ ធូប ៥
- លាជ ៥ កែវ
- ផ្កា ៥ (ថូ ឬ កែវ)
- ស្លាបារីដាក់ជើងពាន ១ គូ
- ចេកនួន ឬចេកណាំវ៉ា ១ គូ
- ពែព្រះកេតុ១ (៣ជ្រុង៣រូត មានកន្ទោង៥ "បាយ១ ម្ហូប២ បង្អែម២ ")
- ពែព្រះកេតុ២ (៣ជ្រុង៩ថ្នាក់រាងជមឈើ មានបាយម្ហូបគ្រប់៩ថ្នាក់)

ដូចនេះ បើប្រៀបធៀបពិធីចូលឆ្នាំបច្ចុប្បន្នទៅពិធីចូលឆ្នាំនៅជំនាន់អង្គរតាមឯកសាររបស់លោក ជាវតាគួន ឃើញមានលក្ខណៈខ្លះឥតប្រែប្រួល ដូចជាស្រង់ព្រះ អុំទូក ហែក្បួន រាំ ជល់សត្វ និងចោលឈូង តែពិធីបច្ចុប្បន្នឃើញមានពីរផ្នែក : មួយបែបទំនៀមបែបពុទ្ធសាសនា និងមួយបែបទៀតបែបព្រាហ្មណ៍សាសនា (ច្រើននៅក្នុងវាំង)។ ប៉ុន្តែខ្មែរនិយមបញ្ចូលទាំងពីរបែប គឺមានបែបពុទ្ធសាសនាផង និងព្រាហ្មណ៍សាសនាផងដូចជាការបន់ស្រន់បួងសួង។ឯខ្មែរនិយមដើរប្រទក្សិណជុំវិញភ្នំខ្សាច់ដូចជានៅក្នុងរឿងសង្ក្រាន្តសូត្រដែលបុត្ររបស់កុបិលមហាព្រហ្មទ្រក្បាលបិតាប្រទក្សិណជុំវិញភ្នំព្រះសុមេរុឃើញថាមានលក្ខណៈឬឥទ្ធិពលពីរឿងតំណាលនោះផង។ ពិធីចូលឆ្នាំខ្មែរមានពីរបែប៖

-តាមបែបសាសនាមានពីរយ៉ាង : ពិធិកសាងវាលុកចេតិយ និងពិធីស្រង់ទឹក
-តាមបែបប្រជាប្រិយមានច្រើនប្រភេទ : សម្តែងរបាំត្រុដិ លេងល្បែងប្រជាប្រិយ រាំកំសាន្ត៕

## រៀនអំណត់

(បទរលកខ្ទប់ច្រាំង - ពាក្យ៩)

កិច្ចសុខុមកុំសូវខឹងប្រឹងខាំមាត់ ហើយសង្កេតហេតុសង្កត់អត់ទោសា
ខុសប៉ុណ្ណឹងខឹងប៉ុណ្ណោះចេះតែថា សូមមើលការសារមើលកាលស្រាលឬធ្ងន់។
ខឹងហួសខ្នាតខាតហួសខ្នាច់ដាច់ដោចគ្នា វិលមកជាវារមកជាប់រាប់ដូចមុន
កាត់មិនដាច់កាត់មិនដឹងខឹងស៊យស៊ន់ គិតកាលមុនគុណកាលមានរៀនអំណត់។

## ចំពោះនារី

(បទពាក្យ៧)

១- នែអង្គនារីរូបប្រសើរ កុំដើរផ្លូវខុសណាំទួនណាំ
ចូរតាំងសណ្ឋិតដោយឥរិយា ការកេរ្តិ៍ពង្សាឋានន្តរ។
២- ជាស្រីគ្មានអ្វីសងគុណម៉ែ រក្សាកេរ្តិ៍ថៃឲ្យថាវរ
ស្មើសងគុណលោកពឧទរ ប្រាកដពន្ធខ្វរខ្វះខ្វាយទៅ។
៣- រូបស្ងួនចិត្តគិតជាក្រមុំ កុំនិយមខុសពីម៉ែឪ
ស្ងួនរក្សាចរិតឲ្យត្រឹមត្រូវ តម្កល់ទុកនូវឱវាទទាន។
៤- ទោះប្រាស្រ័យនឹងនរណានោះ កុំពោលទ្រគោះនាំមោះមាន
មិនគួរស្តីអញមីនាំខឹងខាន ពាក្យតិរច្ឆានកុំថ្លែងចេញ។

សួនកំណាព្យ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## ក្រមុំតូច

(បទពាក្យ៩)

ក្រមុំតូចដូចបទុមក្រពុំពក ប៉ិចពន្លកពីអន្លង់វារីសាយ
ស្រទាប់ព្រឿងលឿងបំព្រងលម្អងខ្វាយ ជាតម្រាយឲ្យភមរាប្រាថ្នាប៉ង។
ក្រេបជញ្ជក់បុប្ផជាតិជូញស្រទាប់ លុះជញ្ជក់ស្កប់ស្កល់ចិត្តចោលជាម្លង
ចូលមកភ្លក់ជាតិមួយភ្លែតឲ្យសៅហ្មង ប្រុសបំណងបែបប៉ុណ្ណឹងចូរដឹងទាន់។
ថាបើមានប្រុសណាមួយចង់មកស្និទ្ធ ត្រូវមើលចិត្តគេឲ្យជាក់កុំបីភាន់
ឯកំលោះនេះក្រឡិចល្បិចច្រើនជាន់ មិនទ្រាន់ស្នូរកន្ទ្រឹសស្នួមស្នេហា។

ឱវាទនារី - បាន គេង ១៩៨៦

## រឿងដើរខ្យល់

ថ្ងៃមួយ លោកមេឃុំម្នាក់បានហៅប្រជាពលរដ្ឋមកចូលរួមប្រជុំ ក្រោមអធិបតីភាពលោកចៅហ្វាយស្រុក នៅឯសាលាឃុំ។ ពេលគាត់ដើរក្បែរចំណោមប្រជារាស្ត្រ ក៏លាន់មាត់ថា៖

- យី! អារំបល់យក័ណាដោមអីក៏ស្អុយខ្លាំងម្ល៉េះ!

បន្តិចក្រោយមកដល់ពេលសម្រាកលោកចៅហ្វាយស្រុកនិងលោកមេឃុំឈរសំណេះសំណាលគ្នាក្បែរចំណោមប្រជារាស្ត្រដដែល ស្រាប់តែលោកចៅហ្វាយស្រុកលេចដោមព្ធសូរ តេត!

លោកមេឃុំក៏ឧទានឡើងថា៖

- ព្រះតេជគុណដើរខ្យល់ស្រួលណាស់!

ប្រជារាស្ត្រ៖ ?!

## រឿងស្មូមចង្អៃក

នាពេលព្រឹកព្រលឹមមួយ ស្មូមម្នាក់ដើរសុំទានតាមដងផ្លូវមួយ គាប់ជួនដើរទៅដល់មុខភូមិគ្រឹះលោកឧកញ៉ាម្នាក់ដែលលកំពុងតែបើកទ្វាររបងចេញទៅហាត់ប្រាណ។ ស្មូមលើកដៃសំពះ ព្រមទាំងនិយាយដោយសុភាពថា៖

ព្រះតេជគុណ! មេត្តាដាក់ទានដល់ខ្ញុំបាទផង ដើម្បីគ្រាន់បានទិញអីហូប ទានប្រោស!

លោកឧកញ៉ានឹកខ្នាញ់ក្នុងចិត្តក៏ស្រែកដាក់ស្មូមទាំងមួរហ្មងថា៖

- ថយចេញ! មើលខ្លួនឲ្យស្អុយគគ្រិច ម៉េចក៏មិនចុះនរកឲ្យបាត់ទៅ

ស្មូមពោលតបវិញថា៖

- ទានប្រោស! ទើបនឹងត្រឡប់មកវិញហ្នឹង បានជាស្អុយហួងអញ្ចឹង

លោកឧកញ៉ាខឹងឆេវឆ្វលចុងច្រមុះ ក្តៅស្លឹកត្រចៀក ក៏តាំងពន្លះស្មូមនោះបន្ថែមថា៖

-អើ! បើបានជាទៅដល់ហើយម៉េចមិននៅរហូតតែម្តងទៅត្រឡប់មកវិញខ្មោចយក៏អី!

ស្មូមញញឹម រួចស្រដីតបដោយទន់ភ្លន់ថា៖

- ទានប្រោស! នៅមិនបានទេទីនោះ ព្រោះពួកឧកញ៉ាដណ្តើមគ្នាទិញដីឋាននរកអស់ទៅហើយទាន!

អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

# វដ្តជីវិតនៃត្រីប៉ាសេអ៊ី និងសមត្ថភាពធម្មជាតិ នៃការសម្របសម្រួលទម្លាប់រស់នៅបន្តពូជពង្សរបស់វា ទៅតាមការប្រែប្រួលនៃបរិស្ថានធម្មជាតិ

## ១. សេចក្តីផ្តើម

នៅចុងសតវត្សទី១៩ និងពេញមួយសតវត្សទី២០ ត្រីទឹកសាបនៅកម្ពុជាត្រូវបានគេទទួលស្គាល់ថាសម្បូរជាងគេក្នុងលោកទាំងបរិមាណនិងប្រភេទ។ ការស្រាវជ្រាវដោយអ្នកវិទ្យាសាស្ត្រ ថានានិច្ឆ័យសាស្ត្រ និងជីវសាស្ត្រជលផលជាតិនិងអន្តរជាតិល្បីៗជាច្រើន ចាប់តាំងពីពាក់កណ្តាល ដល់ចុងសតវត្សទី២០ បានឲ្យដឹងថា ត្រីទឹកសាបនៅកម្ពុជាមានចំនួនជាង៥០០ប្រភេទ ដែលសំណាកគំរូត្រីទាំងនោះ ត្រូវបានគេថែរក្សាទុកនៅកន្លែងរក្សាសំណាកត្រីជាច្រើនប្រទេស ជាពិសេសនៅសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិនៅទីក្រុងប៉ារីសនៃប្រទេសបារាំង យោងទៅតាមអ្នកស្រាវជ្រាវ និងលទ្ធភាព និងគោលការណ៍របស់កន្លែងតម្កល់រក្សាសំណាកទាំងនោះ។

ត្រីទឹកសាបជាច្រើនប្រភេទត្រូវបានទីផ្សារជាតិនិងអន្តរជាតិទទួលស្គាល់ថាមានតម្លៃសេដ្ឋកិច្ចខ្ពស់ក្នុងនោះត្រីប៉ាសេអ៊ីដែលជាប្រភេទត្រីមួយរស់នៅតំបន់ទឹកជួរនៃទន្លេមេគង្គផ្នែកខាងលើ បានក្លាយទៅជាត្រីមួយដែលមានតម្លៃខ្ពស់បំផុតសម្រាប់ទីផ្សាក្នុងស្រុកនាបច្ចុប្បន្ននេះ ដោយសារត្រីនេះមិនសូវសម្បូរ អាចនេសាទបានតែនៅចុងខែវិច្ឆិកាដល់ចុងខែមករា ហើយមានរសជាតិឆ្ងាញ់ ជាពិសេសខ្លាញ់ពោះដែលមានព៌ណលឿងរបស់វា។

កាលពីអំឡុងទសវត្សឆ្នាំ៩០ត្រីប៉ាសេអ៊ីធំៗទម្ងន់ពី១ដល់៣គីឡូក្រាមដែលមានដាក់លក់រាល់ព្រឹកនៅទីផ្សាស្ទឹងត្រែងក្នុងអំឡុងចុងខែធ្នូដល់ចុងខែមករា មានតម្លៃប្រហាក់ប្រហែល ឬថោកជាងត្រីស្រកាផ្សេងៗទៀត ដូចជាត្រីឆ្តោក ត្រីគ្រុំ ត្រីព្រួល ត្រីក្អែកជាដើម( ១0,000៛/គក្រ ) តែចាប់តាំងពីឆ្នាំ២០០០មក ត្រីប៉ាសេអ៊ីបានក្លាយទៅជាត្រីដ៏ពេញនិយមបំផុតសម្រាប់អ្នកទីក្រុងភ្នំពេញដោយសារតែមានការលើកដំណាលឡើងវិញអំពីរសជាតិដ៏ពិសេសនៃខ្លាញ់ពោះព៌ណបៃតងខ្ចីនៃត្រីប៉ាសេអ៊ីនេះតាមរយៈបទសម្ភាសន៍មួយជាមួយអ្នកជំនាញជលផល ដែលផ្សាយតាមកញ្ចក់ទូរទស្សន៍ជាច្រើនដងនៅឆ្នាំ១៩៩៩និងឆ្នាំ២០០០។

ចម្ងល់ជុំវិញខ្លាញ់ពោះព៌ណបៃតងខ្ចីមានរសជាតិឆ្ងាញ់របស់ត្រីប៉ាសេអ៊ីនៅខែធ្នូនិងមករានិងការពុំដែលប្រទះឃើញត្រីនេះធំជាង៤គក្រសោះ បានដិតជាប់ក្នុងអារម្មណ៍អ្នកវិទ្យាសាស្ត្រជលផលតាំងពីទសវត្សឆ្នាំ៨០-៩០មកតែដោយសារបញ្ហាអសន្តិសុខ គ្មានថវិកា ហើយថែមទាំងនៅពេលនោះត្រីប្រភេទនេះនៅមិនទាន់មានតម្លៃខ្ពស់ផងនោះ ការជំរុលចិត្តស្រាវជ្រាវត្រូវបានជម្រុះចោលទៅវិញ។

យ៉ាងណាក៏ដោយឯកសារស្រាវជ្រាវនេះគឺជាការខិតខំប្រឹងប្រែងប្រមែប្រមូលសន្សំទិន្នន័យនិងការចុះយកសំណាកគំរូមកវិភាគតាមគ្រប់រូបភាពដែលអាចធ្វើបានដោយសន្សំសំចៃបំផុតពីមួយឆ្នាំទៅមួយឆ្នាំពីកន្លែងមួយទៅកន្លែងមួយទៀត ទៅតាមលទ្ធភាពផ្ទាល់ខ្លួនរបស់អ្នកនិពន្ធពីឆ្នាំ១៩៩២ដល់១៩៩៩ ដើម្បីបង្គ្រប់លក្ខខណ្ឌតម្រូវនៃវិធីសាស្ត្រវិទ្យាសាស្ត្រ ក្នុងការពិព៌ណនាអំពីវដ្តជីវិតត្រីប៉ាសេអ៊ីដ៏ពេញនិយមរបស់ជនជាតិខ្មែរដែលអាចជឿទុកចិត្តបាន ទុកជូនជាចំណេះដឹងដល់អ្នកជំនាន់នេះនិងអ្នកជំនាន់ក្រោយៗទៀត។

## ២. ថានានិច្ឆ័យសាស្ត្រ (Taxonomy) និងការកំណត់ភិនភាគ (Fish Identification) ត្រីប៉ាសេអ៊ី

ត្រីប៉ាសេអ៊ី( សូមមើលរូបភាព១ )ត្រូវបានអ្នកជំនាញថានានិច្ឆ័យសាស្តព្រឈ្មោះFowlerកំណត់ប្រភេទទៅតាមថានានុក្រម នៅឆ្នាំ១៩៣៧ ដូចខាងក្រោម៖

រជ្ជ ( Kingdom ): Animalia

- អំបូរ ( Phylum ): Chordata
  - សន្តាន ( Class ): Osteichthyes
    - លំដាប់ ( Order ): Cypriniformes
      - ពូជ ( Family ): Cyprinidae
        - ពួក ( Genus ): Mekongina
          - ប្រភេទ ( Species ): M. erythrospila ( Fowler, 1937 )

តាមការបង្ហាញរបស់លោកបណ្ឌិត Walter J. Rainboth, 1996[1] ត្រីប៉ាសេអ៊ីគឺជាត្រីស្រកាមានឆ្អឹងក្នុងសាច់ ដែលមានភិនភាគពិសេសដូចតទៅ៖ ( ១ )ព្រុយខ្នងគ្មានផ្លុង ( ២ )ទ្រនង់ព្រុយខ្នងមានចំនួន១០ ( ៣ )គ្មានព្រុយពុកមាត់ ( ៤ )ក្រអូមមាត់ខាងលើលយលើសខាងក្រោមគ្របដោយស្បែកអុចៗ។ ត្រីប៉ាសេអ៊ីស៊ីហ្វីតូប្លង់តុង និងប៉េរីហ្វីតុង ( សារាយដែលមានសារធាតុចំរុះនៃកំទិចកំទីស្លែរនិងរុក្ខជាតិរលួយដុះជាប់ថ្មនៅបាតគន្លងផ្លូវទឹកដែលថ្លា និងហូរខ្លាំង ) ។



រូបភាព១. ត្រីប៉ាសេអ៊ី អាយុពីរឆ្នាំទម្ងន់១,៤គីឡូក្រាម ពេញវ័យបន្តពូជពង្ស ( ស្រកាប្រែជាព័ណក្រហមព្រឿង )

## ៣. វិធីសាស្ត្រស្រាវជ្រាវអង្កេតពីដំណើរជីវិត និងការធ្វើបន្លាស់ទីរបស់ត្រីប៉ាសេអ៊ី ( ១៩៩៤-១៩៩៩ )

សម្ភារៈត្រៀមសម្រាប់ការស្រាវជ្រាវមាន៖ សម្ភារៈវះកាត់ត្រី កែវពង្រីក ឧបករណ៍វាស់ជំរៅទឹកនិងស្វែងរកត្រី ( ecosounder and fish finder ) ឧបករណ៍ពិនិត្យគុណភាពទឹក សាច់អួនក្រឡាញឹក និងម្សៅរ៉ូតាណុន។

### ៣.១. ការប្រមូលព័តមានពីប្រជាពលរដ្ឋមូលដ្ឋាន

ការស្រាវជ្រាវអង្កេតនេះ បានចាប់ផ្តើមពីការប្រមូលព័តមានពីប្រជាជនមូលដ្ឋានដែលធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់នេសាទបាន និងធ្លាប់បរិភោគត្រីប៉ាសេអ៊ី ជាពិសេសអ្នកដែលរស់នៅជាប់ឬក្បែរស្ទឹង ទន្លេ បឹងបួរ ដែលត្រីប្រភេទនេះតែងតែរស់នៅ ឬចេញចូល ឬធ្លាប់ឆ្លងកាត់ម្តងម្កាល។ បន្ទាប់មកប្រមូលពត៌មានពីអ្នកនេសាទ និងអ្នកលក់ត្រី ទាំងនៅទីផ្សារសំខាន់ៗ ទាំងនៅទីផ្សារតូចៗតាមភូមិ។ កិច្ចការនេះត្រូវបានបញ្ចប់នៅឆ្នាំស្រាវជ្រាវតំបូងៗ( ១៩៩២-៤ ) ដោយបានធ្វើការបញ្ជាក់ពត៌មាននិមួយៗ ជាច្រើនលើកច្រើនសារដើម្បីកំណត់ភាពត្រឹមត្រូវរបស់ពត៌មានទាំងនោះ។

ត្រីប៉ាសេអ៊ីអាចនេសាទបានតែដោយឧបករណ៍លបផ្សំព្រួលតាមប្រាំងទន្លេនៅរដូវវស្សា និងមងនៅគ្រប់រដូវតាមដងទន្លេមេគង្គ ទន្លេសេកុង ទន្លេសេសាន និងទន្លេស្រែពក។ ត្រីត្រូវបានកំណត់ជា៥ក្រុមទៅតាមភាពញឹកញាប់នៃក្រុមដែលមានទំហំប្រហាក់ប្រហែលគ្នាដែលប្រទះឃើញ៖ ( ក្រុម១ ) ត្រីទំហំចាប់ពី ១,៣គក្រ ឡើងទៅ ( ក្រុម២ ) ត្រីទំហំពី០,៨ ដល់ ១,២គក្រ ( ក្រុម៣ ) ត្រីទំហំពី០,៣ ដល់០,៧គក្រ ( ក្រុម៤ ) ត្រីទំហំតូចជាង ០,២គក្រ និង( ក្រុម៥ ) កូនត្រី។

### ៣.២. ការចុះប្រមូលយកសំណាកគំរូដល់មូលដ្ឋានពីអ្នកនេសាទ ពីអ្នកលក់ត្រី និងពីការនេសាទខ្លួនឯង

ការចុះយកគំរូជាក់ស្តែងនៅតាមតំបន់នេសាទដែលត្រីនេះបង្ហាញខ្លួន ដោយទិញត្រីនេះពីអ្នកនេសាទយកមកវះកាត់ពិនិត្យវិភាគកម្រិតខ្លាញ់ក្នុងពោះ កម្រិតចំណីក្នុងក្រពះនិងពោះវៀន និងកម្រិតក្រពេញបន្តពូជ។ ជាសំណាងស្ទើរតែគ្រប់ពេលទាំងអស់អ្នកនេសាទតែងផ្តល់ត្រីតូចៗ( ០,២-០,៣គក្រ/ក្បាល ) ដល់ការស្រាវជ្រាវដោយមិនគិតថ្លៃ។កន្លែងនេសាទដែលចុះប្រមូលសំណាកគំរូត្រីមកវះកាត់វិភាគមាន៖( ត១ )ចំណុចអតីត

[1] Walter J. Rainboth, 1996. Fish of the Cambodian Mekong. Published by MRC, FAO, DANIDA

ស្ពានឆ្លងទន្លេសេសានខេត្តស្ទឹងត្រែង (ត២) ទន្លេមេគង្គចំណុចចុងកោះកន្ទុយគោទល់មុខទីរួមខេត្តស្ទឹងត្រែង **(ត៣) ទន្លេមេគង្គចំណុចតំបន់ទឹកជ្រៅនៃប្រជុំកោះស្នាមជ័យ កោះស្រឡៅ និងកោះស្នែង; (ត៤) ទន្លេមេគង្គ** ចំណុចស្រុករីនខាំខាងក្រោមល្បាក់ខោនប្រទេសឡាវ (ត៥) ទន្លេមេគង្គចំណុចត្បូងខ្លាខេត្តស្ទឹង ត្រែង (ត៦) ទន្លេមេគង្គចំណុចខ្សាច់ម្កាក់ខេត្តក្រចេះ (ត៧) ទន្លេសេកុងចំណុចស្រុកសៀមប៉ាង (ត៨) ទន្លេសេកុងចំណុច ខេត្តអាតាពើ ប្រទេសឡាវ (ត៩) ទន្លេសេកុងចំណុចខេត្តសេកុងប្រទេសឡាវ (ត១០) ទន្លេសេសានចំណុច ស្រុកវីរៈជ័យ ខេត្តស្ទឹងត្រែង (ត១១) ទន្លេស្រែពកចំណុចស្រុកលំផាត់ខេត្តរតនគីរី និង(ត១២) ទន្លេស្រែពក ចំណុចស្រុក កោះញែកខេត្តមណ្ឌលគីរី។

នៅពេលខ្លះត្រីត្រូវបានទិញពីអ្នកនេសាទនៅកន្លែងឡើងត្រីនៅទីរួមខេត្តស្ទឹងត្រែងពេលទៀបភ្លឺជាមួយ ការសាកសួរពីប្រភពត្រីផងដែរ។ពេលខ្លះទៀតត្រីត្រូវបានទិញពីអ្នកលក់ត្រីនៅក្នុងទីផ្សាស្ទឹងត្រែងដែលពត៌មាន ពីប្រភពត្រីដែលទទួកបានពុំសូវត្រឹមត្រូវឡើយ។មានម្តងម្កាលត្រីត្រូវបានទិញពីអ្នកលក់នៅតាមទីផ្សាក្នុងភូមិ ដែលប្រភពច្បាស់លាស់របស់វា អាចទទួលយកបានពីអ្នកលក់។

នៅពេលខ្លះទៀត ជាពិសេសនៅពេលដែលមានការបាត់មុខក្រុមត្រីធំៗពីក្នុងហ្វូង ចាប់ពីចុងខែមករា រហូតដល់ចុងខែមិថុនានោះកន្លែងដែលគ្របដណ្តប់ទៅដោយថ្មរកេតរកូតក្នុងទន្លេមេគង្គចាប់ពីកោះស្នាមជ័យ ដល់កោះស្រឡៅនិងកោះស្នែងប៉ែកខាងលើទីរួមខេត្តស្ទឹងត្រែង (ត៣) ដែលមិនដែលមានការនេសាទសោះ នោះត្រូវបានជ្រើសរើសសម្រាប់នេសាទស្វែងរកត្រីដោយក្រុមអ្នកស្រាវជ្រាវដើម្បីដោះស្រាយចម្ងល់ដែលនៅ សេសសល់។ ការនេសាទនេះត្រូវប្រើម្សៅរ៉ូតាណុន(វល្លិម្យ៉ាងដែលមានជាតិពុលដែលជនជាតិភាគតិចតែង ប្រើសម្រាប់បំពុលត្រីក្នុងទឹកឲ្យសន្លប់ដើម្បីចាប់យកទៅធ្វើម្ហូបបរិភោគ)រោយនៅកន្លែងដែលមានថ្មរកេតរកូត ស្មុគស្មាញ ហើយយកអួនអញ្ចងក្រឡាល្អិតចាំត្រងចាប់ត្រីដែលសន្លប់ដោយម្សៅខាងលើ នៅផ្នែកខាងក្រោម ទឹក។ត្រីទាំងធំទាំងតូចដែលសំងំលាក់ខ្លួនក្នុងតំបន់ថ្មរកេតរកូតនេះត្រូវបានត្រងចាប់ទាំងអស់យកមកកំណត់ ភិនភាគប្រភេទ ដើម្បីរកឲ្យឃើញចម្លើយដោះស្រាយចម្ងល់ និងធ្វើការវះកាត់ពិនិត្យវិភាគដូចសព្វមួយដង។

នៅពេលទឹកទន្លេមេគង្គ ទន្លេសេកុង និងទន្លេសេសានប្រែជាល្អក់នៅរដូវវស្សានោះ ត្រីប៉ាសេអ៊ីក៏បាន បាត់មុខពីទន្លេទាំងនោះដែរ ដូច្នេះទន្លេស្រែពកត្រូវបានកំណត់ថាជាចំណុចស្រាវជ្រាវចុងក្រោយ។ ការរុករក ត្រូវជួបការលំបាកខ្លាំងដោយនៅរដូវប្រាំងកំណាត់ទន្លេចាប់ពីស្រុកលំផាត់ឡើងទៅលើមានកន្លែងថ្មរកេតរកូត គោកដាច់ទឹកជាច្រើនកន្លែង។ឯនៅរដូវវស្សាវិញកំណាត់ទន្លេក្នុងស្រុកកោះញែកមានចរន្តទឹកហូរខ្លាំងនៅពេល មានភ្លៀងធំម្តងៗ។ ម៉្យាងទៀតនៅតាមដងទន្លេមានព្រៃឬស្សីដុះយ៉ាងក្រាស់ស្មើរ តែមើលមិនឃើញមាត់អូរ តូចៗនៃតំបន់រងទឹកភ្លៀងរបស់ទន្លេស្រែពក ដែលក្រោយមកការស្រាវជ្រាវបានសន្និតថាជាកន្លែងដែលត្រី ប៉ាសេអ៊ី ឡើងទៅបងកូននៅពេលដែលមានទឹកជំនន់ភ្នំក្រោពេលមានភ្លៀងធំម្តងៗ នៅអំឡុងចុងខែកក្កដា និងខែសីហា(ជំនន់ដែលកើតឡើងយ៉ាងលឿននៅតាមអូរនៃតំបន់នោះ ក្រោយពេលមានភ្លៀងធំហើយ ២-៣ ថ្ងៃក្រោយមក ស្រកទៅវិញ)។ កំណាត់ទន្លេស្រែពកចាប់ពីចំណុចសាមុត្រក្រោមរហូតដល់ព្រំប្រទល់កម្ពុជា-វៀតណាមមានប្រវែងប្រហែល១០០គីឡូម៉ែត្រគឺជាកំណាត់ទន្លេដែលមានលក្ខណៈពិសេសខុសប្លែកគេដោយ បាតទន្លេស្ទើរតែទាំងស្រុងក្រាលដោយកំរាលថ្មធម្មជាតិ ហើយជាង៣០%នៃកំណាត់ទន្លេនេះ គ្របដណ្តប់ទៅ ដោយកន្លែងទឹកជ្រៅ ដែលមានថ្មរកេតរកូត និងអន្លង់ជ្រៅៗចំនួន១១កន្លែង ជាពិសេសទៅទៀត តំបន់នេះនៅ មិនទាន់មានការហូរច្រោះ ដែលធ្វើឲ្យគុណភាពទឹកនៅចន្លោះកំណាត់ទន្លេនេះនៅរក្សាភាពថ្លារបស់វាជាមួយ កំហាប់អុកស៊ីហ្សែនខ្ពស់ខួបប្រាំងខួបវស្សាគ្មានការរំខានពីការតាំងលំនៅដ្ឋានរបស់មនុស្សនិងការនេសាទដែល ធ្វើឲ្យតំបន់នេះក្លាយទៅជាជំរកដ៏ពិសិទ្ធជាពិសេសនៅរដូវវស្សារបស់ត្រីប៉ាសេអ៊ី និងត្រីប្រចាំតំបន់ ផ្សេងទៀត ដូចជាត្រីប៉ាវាមុខពីរ ត្រីប៉ាវា ត្រីបុងឡាវ ត្រីក្រាយឆ្នូតជាដើម និងត្រីធ្វើបន្លាស់ទី ឆ្ងាយមួយចំនួន ដូចជាត្រសក់ ត្រីព្រួល ត្រីក្បក ត្រីប្រា ត្រីប្រាកណ្តុរ ត្រីកែ ត្រីគ្រំ ជាដើម។ សកម្មភាពស្រាវជ្រាវ ត្រូវបានអនុវត្ត នៅក្នុងខែ សីហាតាមការប្រើ ឧបករណ៍ស្វែងរកត្រីតាមអន្លង់ដើម្បីរាយមង (៤ប្រភេទ) ក្រឡា៤, ៦, ៨និង១២សម។ ត្រី ច្រើនប្រភេទបានជាប់មងក្នុងនោះក៏មានត្រីប៉ាសេអ៊ីចាប់ពីទំហំ០,២ដល់៣គក្រដែរដែលត្រីធំចាប់ពី១,២គក្រ

ឡើងទៅ មានក្រពេញបន្តពូជកម្រិត៤(កម្រិតជិតដល់ពេលទម្លាក់ពង) និងក្រោយកម្រិត៤ (កម្រិតដែលទម្លាក់ពងលើកទី១រួចហើយ នៅរង់ចាំទម្លាក់លើកទី២ពងចុងក្រោយ) ឯកូនត្រីទើបញាស់ដែលត្រងបាននៅមាត់អូរក្រោយជំនន់ភ្នំនៅមិនទាន់អាចសម្គាល់បាននៅឡើយនៅពេលនោះព្រោះនៅតូចពេកដោយទើបតែមានអាយុ១-២ថ្ងៃប៉ុណ្ណោះ។

កិច្ចការទាំងអស់ក្នុងចំណុច៣.២នេះត្រូវបានអនុវត្តក្នុងអំឡុងឆ្នាំ១៩៩២-៩៨ដែលអាចធ្វើការសង្ខេបអំពីវត្តមានតាមទីកន្លែងនិងស្ថានភាពរបស់ត្រីនេះ ក្នុងតារាងខាងក្រោម៖

**<u>តារាង១. ការបង្ហាញខ្លួនរបស់ត្រីប៉ាសេអ៊ីពីកន្លែងមួយទៅកន្លែងមួយទៀតទៅតាមពេលវេលា</u>**

| តំបន់ / ខែ | (ក១) | (ក២) | (ក៣) | (ក៤) | (ក៥) | (ក៦) | (ក៧) | (ក៨) | (ក៩) | (ក១០) | (ក១១) | (ក១២) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| វិច្ឆិកា | ១/២ | | | | | | | | | | | |
| ធ្នូ | ២/៣/៤ | ១/២/៣/៤ | | | | | | | | | | |
| មករា | | ១/២/៣/៤ | | | | | | | | | | |
| កុម្ភៈ | | | ១/៥ | ៣/៤ | | | ២/៣ | ២/៣ | ២/៣ | | | |
| មិនា | | | ១/៥ | ៣/៤ | | | ២/៣ | ២/៣ | ២/៣ | | | |
| មេសា | | | | ៣/៤ | ៤/៥ | ៤/៥ | ២/៣ | ២/៣ | ២/៣ | | | |
| ឧសភា | | | | | ៤/៥ | ៤/៥ | | | | | | |
| មិថុនា | | | | | | | | | | ២/៣ | ២/៣/៤ | ១/៣/៤ |
| កក្កដា | | | | | | | | | | | ៣ | ១/២/៤ |
| សីហា | | | | | | | | | | | ២/៣/៤ | ១/៤/៥ |
| កញ្ញា | | | | | | | | | | | ២/៣/៤ | ១/៤/៥ |
| តុលា | | | | | | | | | | | ១/២/៣ | ៣/៤/៥ |

<u>**កំណត់សំគាល់៖**</u> -*(ក១)* ដល់ *(ក១២)* គឺជាតំបន់ដែលត្រីប៉ាសេអ៊ីបង្ហាញខ្លួនកំណត់នៅក្នុងវាក្យខណ្ឌ១ នៃចំណុច៣.២ ។

-*១, ២, ៣, ៤, ៥* តំណាងឲ្យត្រី នៃក្រុម១, ក្រុម២, ក្រុម៣, ក្រុម៤, និងក្រុម៥, ដែលកំណត់នៅក្នុងវាក្យខណ្ឌ២ នៃចំណុច៣.១ ។

- (ពណ៌ទឹកក្រូច) តំបន់ *(ក១)* ដល់ *(ក៦)* **ថិតនៅក្នុងទន្លេមេគង្គដែលទឹកប្រែជាល្អក់ពីខែមិថុនាដល់តុលា។**

- (ពណ៌ក្រហម) **ដំណាក់កាលពងកូន ដែលត្រីមេ ឈ្មោលត្រូវទៅរកកន្លែងថ្មរកេតរកូតមានទឹកថ្លា និងហូរខ្លាំង ។**

តារាង១ ខាងលើបង្ហាញថា ត្រីប៉ាសេអ៊ីធំៗបានបង្ហាញខ្លួននៅចំណុចប្រសព្វនៃទន្លេសេសាន និងទន្លេសេកុងនៅខែវិច្ឆិកានិងខែធ្នូគឺនៅចំពេលដែលទឹកទន្លេទាំងពីរប្រែពីល្អក់ទៅជាថ្លាហើយត្រីទាំងតូចទាំងធំបានមកប្រមូលផ្តុំនៅចំណុចប្រសព្វទន្លេមេគង្គនិងទន្លេសេកុងនៅខែធ្នូ-ខែមករា ក៏នៅចំពេលដែលទឹកទន្លេមេគង្គបានប្រែពីល្អក់មកថ្លាដែរ។ នៅចុងខែមករា ត្រីប៉ាសេអ៊ីធំៗក្នុងវ័យបន្តពូជពង្សត្រូវចូលទៅសំងំនៅអន្លង់ជ្រៅៗ ដើម្បីឲ្យក្រពេញបន្តពូជរីកលូតលាស់អាចពងកូនបាននៅតំបន់ទឹកជ្ជរខាងជើងទីរួមខេត្តស្ទឹងត្រែងនៅក្នុងខែមីនា។

ត្រីតូចៗ បែកចេញជា២ហ្វូង៖ ហ្វូងដែលមានទំហំតូចជាង០,៧គក្រ ធ្វើដំណើរឡើងទៅចំណុចវីនខាំខាងក្រោមល្បាក់ខោនប្រទេសឡាវឯមួយហ្វូងទៀតដែលមានទំហំចាប់០,៥គក្រទៅ១គក្របានធ្វើដំណើរតាមទន្លេសេកុងកាត់តាមតំបន់សៀមប៉ាងឆ្ពោះទៅចំណុចអាតាពើនិងជាចុងក្រោយទៅចំណុចខេត្តសេកុងប្រទេសឡាវនៅក្នុងខែកុម្ភៈ មីនា និងមេសា ដើម្បីស៊ីចំណីនៅទីនោះ។

កូនត្រីដែលទើបនឹងញាស់នៅចុងខែកុម្ភៈ និងខែមីនា បានចាកចេញតំបន់ទឹកជ្ជរខាងជើងទីរួមខេត្ត

ស្ទឹងត្រែងនៅខែមេសា ដើម្បីចុះទៅតំបន់ទឹកជ្រៅប៉ែកខាងក្រោមស្វែងរកស៊ីចំណីនៅចំណុចត្បូងខ្លា ខាងត្បូងទីរួមខេត្តស្ទឹងត្រែង ហើយបន្តទៅចំណុចទឹកជ្រៅខ្សាច់ម្កាក់ខាងជើងទីរួមខេត្តក្រចេះនៅខែឧសភា។ នៅពេលទឹកទន្លេមេគង្គ ទន្លេសេកុង និងទន្លេសេសានចាប់ផ្ដើមល្អក់នៅខែមិថុនា ត្រីប៉ាសេអ៊ីទាំងតូច ទាំងធំបានធ្វើដំណើរទៅរកកន្លែងទឹកថ្លានៅទន្លេស្រែពក ហើយបន្តរស់នៅក្នុងតំបន់ទឹកជ្រៅដែលមានទឹកថ្លាជាប់ជានិច្ចដើម្បីស៊ីចំណីរីកធំធាត់និងបន្តពូជពង្សរហូតដល់វិច្ឆិកាពេលដែលទឹកទន្លេចាប់ផ្ដើមស្រកទើបនាំគ្នាចាកចេញទៅរកទន្លេមេគង្គវិញដោយត្រូវធ្វើដំណើរកាត់តាមទន្លេសេសាននិងទន្លេសេកុង(សូមមើលរូបភាព២)។

### ៣.២.១. លទ្ធផលនៃការវះកាត់ពិនិត្យវិភាគ កម្រិតខ្លាញ់ក្នុងពោះ កម្រិតចំណីក្នុងក្រពះនិងក្នុងពោះវៀន និងកម្រិតក្រពេញបន្តពូជ

ត្រីដែលទិញពីអ្នកនេសាទត្រូវបានវះកាត់ពិនិត្យកំរិតខ្លាញ់ក្នុងពោះ ចំណីក្នុងក្រពះ និងក្នុងពោះវៀន និងក្រពេញបន្តពូជ ដើម្បីអាចដឹងអំពីស្ថានភាពនៃកន្លែងរស់នៅរបស់ពួកវានិមួយៗ ដែលទាក់ទងនឹងការធ្វើបន្លាស់ទីរបស់វា។ ខ្លាញ់ពោះ ចំណីក្នុងក្រពះ និងក្នុងពោះវៀន អាចបញ្ជាក់ពីភាពសម្បូរនៃចំណីដែលមាននៅកន្លែងដែលវាឈប់សំចតមួយរយៈពេលរហូតដល់ពេលធ្វើបន្លាស់ទីទៅកន្លែងដទៃទៀត។ពេលខ្លះដោយសារធម្មជាតិប្រែប្រួលទើបតម្រូវឲ្យមានការធ្វើបន្លាស់ទីទៅរកកន្លែងថ្មី ដែលអំណោយដល់ទម្លាប់រស់នៅរបស់វា។ ឯក្រពេញបន្តពូជ និងខ្លាញ់ពោះក៏អាចជួយឲ្យបានដឹងពីស្ថានភាពមុននិងក្រោយពេលពងកូន ដែលអាចនាំទៅដល់ការរកឃើញកន្លែងពងកូនរបស់វាទៀតផង។

ចំនួនត្រីគ្រប់ខ្នាតដែលបានជ្រើសរើសយកមកវះកាត់នៅតាមកន្លែងកំណត់ទាំង១២កន្លែងមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំព្រោះតម្រូវការទីផ្សាកាន់ខ្លាំងតម្លៃត្រីកាន់តែខ្ពស់ពិបាករកទិញយកមកវះកាត់។ទោះជាបរិមាណត្រីដែលទិញយកមកវះកាត់មានចំនួនតិចនាប៉ុន្មានឆ្នាំចុងក្រោយក៏ដោយក៏ស្ថានភាពប៉ារ៉ាម៉ែត្រដែលតាមដាននៅតែរក្សាភាពមិនប្រែប្រួលដែលអាចប្រើទិន្នន័យមធ្យមភាគដាក់បញ្ចូលក្នុងតារាងតែមួយបាន៖

តារាង២. កំរិតខ្លាញ់ពោះ កំរិតចំណីក្នុងក្រពះ និងពោះវៀន និង កំរិតក្រពេញបន្តពូជ

| ខែ | កំរិតខ្លាញ់ពោះ (ខ) កំរិតចំណីក្នុងក្រពះ (ក) កំរិតចំណីក្នុងពោះវៀន (ព) កំរិតក្រពេញបន្តពូជ (ប) | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ក្រុម១ | | | | ក្រុម២ | | | | ក្រុម៣ | | | | ក្រុម៤ | | | ក្រុម៥ | |
| | ខ | ក | ព | ប | ខ | ក | ព | ប | ខ | ក | ព | ប | ខ | ក | ព | ក | ព |
| វិច្ឆិកា | ៤ | ៣ | ៤ | ០ | ៤ | ៤ | ៣ | ០ | ៣ | ៣ | ៤ | ០ | ៣ | ៤ | ៣ | - | - |
| ធ្នូ | ៤ | ៣ | ៣ | ០ | ៤ | ៣ | ៣ | ០ | ៣ | ៣ | ៣ | ០ | ៤ | ៣ | ៤ | - | - |
| មករា | ៣ | ២ | ២ | ២ | ៣ | ៣ | ៤ | ០ | ២ | ២ | ៣ | ០ | ៣ | ២ | ៣ | - | - |
| កុម្ភៈ | ២ | ១ | ១ | ៣ | ២ | ៣ | ៣ | ០ | ២ | ៣ | ៣ | ០ | ២ | ២ | ៣ | - | - |
| មិនា | ១ | ០ | ១ | ៤ | ២ | ២ | ៣ | ០ | ៣ | ៤ | ៣ | ០ | ២ | ៣ | ៣ | ១ | ០ |
| មេសា | ០ | ១ | ០ | ០ | ២ | ៣ | ៣ | ០ | ៣ | ៣ | ៤ | ០ | ៣ | ៣ | ៤ | ២ | ១ |
| ឧសភា | ១ | ២ | ៣ | ០ | ២ | ២ | ៤ | ១ | ២ | ៤ | ៣ | ០ | ១ | ២ | ៣ | ២ | ២ |
| មិថុនា | ២ | ៣ | ៤ | ១ | ២ | ២ | ៣ | ២ | ១ | ២ | ២ | ០ | ០ | ១ | ២ | ១ | ០ |
| កក្កដា | ២ | ៣ | ៣ | ៣ | ១ | ១ | ២ | ៣ | ២ | ២ | ៣ | ០ | ១ | ២ | ៣ | ២ | ២ |
| សីហា | ១ | ១ | ២ | ៤ | ០ | ១ | ០ | ៤ | ២ | ៣ | ៤ | ០ | ២ | ២ | ៣ | ២ | ៣ |
| កញ្ញា | ០ | ៣ | ៣ | ០ | ១ | ៣ | ២ | ០ | ៣ | ៣ | ៤ | ០ | ២ | ៣ | ៤ | ៣ | ៤ |
| តុលា | ២ | ៣ | ៤ | ០ | ២ | ៣ | ៤ | ០ | ៣ | ៤ | ៣ | ០ | ៣ | ៤ | ៣ | ៣ | ៣ |

កំណត់សំគាល់៖

- ខ្លាញ់ពោះតំណាងដោយផ្ទួរឈរអក្សរ ខ មាន៥កំរិត (០ គ្មានខ្លាញ់ ១ មានខ្លាញ់តិចតួច ២ មានខ្លាញ់៥០% ៣ មានខ្លាញ់៧០% ៤ មានខ្លាញ់ពេញណែនពោះ)។
- ចំណីក្នុងក្រពះតំណាងដោយផ្ទួរឈរអក្សរ ក មាន៥កំរិត (០ គ្មានចំណីសោះ ១ មានចំណីតិចតួច ២ មាន ចំណី៥០% ៣ មានចំណីពេញក្រពះ ៤ មានចំណីប៉ោងពេញក្រពះ)។
- ចំណីក្នុងពោះវៀនតំណាងដោយផ្ទួរឈរអក្សរ ព មាន៥កំរិត (០ គ្មានចំណី សោះ ១ មានចំណីតិចតួច ២ មានចំណី៥០% ៣ មានចំណីពេញល្មម ៤ មានចំណីពេញណែនពោះវៀន)។

- គ្រពេញបន្តរពូជតំណាងដោយជួរឈរអក្សរ ប មាន៥កំរិត (០ មិនទាន់រីកលូតលាស់ ១ ចាប់ផ្ដើមរីកលូតលាស់ ២ រីកលូតលាស់ជាផ្លូតផ្ទាំងគ្រពេញព៌ណផ្កាឈូក ៣ រីកលូតលាស់ដោយចេញជាគ្រាប់ៗ នៅលើផ្ទាំង គ្រពេញ ៤ គ្រាប់នៅលើផ្ទាំងគ្រពេញលេញចេញកាន់តែច្បាស់ និងមានចំណុចខ្មៅនៅតាមគ្រាប់និមួយៗផង)។
- ជួរផ្ដេកព៌ណលឿងបង្ហាញអំពីដំណាក់កាល ដែលប្រទះឃើញត្រីប៉ាសេអ៊ីទាំងអស់មានខ្លាញ់ព៌ណបៃតងខ្ចី ក្រោយពេលចាកចេញពីទន្លេស្រែពក ដោយសារប៉េរីហ្វីតុងដែលវាស៊ីនៅទីនោះមានលក្ខណៈពិសេសខុសគេ។
- ជួរផ្ដេកព៌ណត្នោតបង្ហាញអំពីដំណាក់កាលពងកូនរបស់ត្រីប៉ាសេអ៊ី។

តារាង២បានបង្ហាញឲ្យឃើញថាត្រីទាំងធំទាំងតូចនៅក្នុងខែវិច្ឆិកា ធ្នូ និងមករា ដែលបង្ហាញខ្លួននៅចំណុចប្រសព្វនៃទន្លេសេសាន-សេកុង និងចំណុចប្រសព្វនៃទន្លេមេគង្គ-សេកុងមានផ្ទុកសារធាតុខ្លាញ់ពេញពោះ និងចំណីក្នុងក្រពះនិងពោះវៀនយ៉ាងច្រើន។ នៅអំឡុងខែកុម្ភៈ-មីនា ខ្លាញ់ពោះ និងចំណីក្នុងក្រពះនិងពោះវៀន នៃត្រីពេញវ័យបានថយចុះយ៉ាងច្រើនដោយសារតែជាពេលពងកូន។ តែត្រីទំហំតូចជាង១គ.ក្រ នៅរក្សាខ្លាញ់ពោះ ចំណីក្នុងក្រពះ និងពោះវៀនក្នុងកំរិតខ្ពស់គួរសមតែខ្លាញ់ប្រែជាព៌ណសដោយសារគុណភាពចំណីខុសគ្នា ហើយនៅតែរក្សាកំរិតមធ្យមរហូតដល់ខែសីហាទើបចាប់ផ្ដើមកើនឡើងវិញ។ដោយឡែកខ្លាញ់ពោះចំណីក្នុងក្រពះពោះវៀននៃត្រីធំៗបានកើនឡើងយ៉ាងរហ័សចាប់ពីខែមេសាដល់ខែកក្កដាទើបធ្លាក់ចុះវិញដោយសារតែពេលពងកូន។ ខ្លាញ់ពោះ និងចំណីក្នុងក្រពះ ពោះវៀននៃត្រីទាំង អស់ បានចាប់ផ្ដើមកើនឡើងដល់កំរិតខ្ពស់បំផុតចាប់ពីខែកញ្ញាដល់ខែវិច្ឆិកា ដែលមានន័យថាចំណីបានកកើតឡើងយ៉ាងខ្លាំងនៅក្នុងដំណាក់កាលនេះ។



រូបភាព២. ផែនទីបង្ហាញអំពីកន្លែងពងកូន និងពេលនាធ្វើបម្លាស់ទីក្នុងឆ្នាំរបស់ត្រីប៉ាសេអ៊ី

### ទិដ្ឋភាពរួបដែលគួរឲ្យកត់សម្គាល់ និងការពិភាក្សា

នៅអំឡុងពេលស្រាវជ្រាវនេះមានចំណុចគួរឲ្យកត់សំគាល់៣ចំណុចៈ (១)មិនដែលជួប និងមិនដែលទទួលបានពត៌មានថាធ្លាប់ឃើញត្រិប៉ាសេអ៊ីធំជាង៤គក្រ(២)ត្រីប៉ាសេអ៊ីមានទំហំចាប់ពី១,២-១,៣គក្រឡើងទៅបានប្រែព៌ណពីសប្រផេះទៅជាក្រហមព្រឿងដោយមានអុចក្រហមចាស់នៅលើស្រកាផងហើយនៅក្រោយរដូវពងកូននៅខែមីនា និងសីហានៃឆ្នាំ ត្រីធំៗមួយចំនួនត្រូវបានប្រទះឃើញថាមានព៌ណខ្មៅនៅខាងខ្នង (៣)ត្រីប៉ាសេអ៊ីចាប់ពីទម្ងន់០,៥គក្រឡើងទៅ តែងតែប្រទះឃើញថាមានខ្លាញ់ពោះព៌ណបៃតងខ្ចីនៅអំឡុងខែវិច្ឆិកាដល់កុម្ភៈហើយមានរសជាតិឆ្ងាញ់ក្រៅពីពេលនេះខ្លាញ់ពោះត្រីជាទូទៅមានព៌ណសធម្មតាដែលតាមមតិទូទៅជាពិសេសអ្នកស្រុកមូលដ្ឋានដែលត្រីនេះរស់នៅទាំងនៅកម្ពុជានិងឡាវបាននិយាយថារស់ជាតិវាមិនឆ្ងាញ់ដូចនៅក្នុងខែវិច្ឆិកាមករាទេ។

ចំណុច(១)ត្រីប៉ាសេអ៊ីដែលធ្លាប់ប្រទះឃើញមានទម្ងន់៣,៥គក្រមានអាយុប្រហែល៦ឆ្នាំមានន័យថាការធំធាត់របស់វាយឺត ដោយសារតែហ្សែន និងទម្លាប់រស់នៅស៊ីចំណីមានលក្ខខណ្ឌកំហិតដែលតម្រូវឲ្យធ្វើបន្លាស់ទីជាហ្វូងច្រើនដងទៅច្រើនកន្លែងក្នុងមួយឆ្នាំៗដែលងាយឲ្យអ្នកនេសាទចាប់បានមិនដូចត្រីប៉ាវ៉ាមុខពីរ និងត្រីប៉ាវ៉ាដែលរស់នៅក្នុងជំរកប្រហាក់ប្រហែលគ្នា តែធ្វើបន្លាស់ទីតិច និងមិនរើសចំណីពេលទេ ដែលធ្វើឲ្យ

ពួកវាមានសំណាងអាចគេចផុតពីការនេសាទបានច្រើនជាង។ ត្រីទាំង២ប្រភេទខាងក្រោយនេះធ្លាប់ត្រូវបានប្រទះឃើញធំរហូតដល់ជាង១០គក្រ(ត្រីប៉ាវ៉ា) និងដល់ជាង៣០គក្រ(ត្រីប៉ាវ៉ាមុខពីរ) ដែលមានន័យថាពួកវាអាចរស់នៅបានដល់អាយុពីជាង១០ ទៅជាង៣០ឆ្នាំ។

ចំណុច (២)ការប្រែព៌ណរបស់ត្រីប៉ាសេអ៊ីបញ្ជាក់ពីការពេញវ៉ៃយដែលបន្តរពូជពង្សបាន ឯការឡើងព៌ណខ្មៅផ្នែកខាងខ្នងគឺជាការបង្ហាញពីដំណាក់កាលពងកូនរបស់ត្រីពេញវ៉ៃយ។

ចំណុច(៣)ខ្លាញ់ពោះត្រីប៉ាសេអ៊ីព៌ណបៃតងខ្ចីនៅអំឡុងខែវិច្ឆិកា-មករាអាចប្រហែលមកពីភាពសម្បូរនៃសារាយប៉េរីហ្វិតុងជាចំណីមានគុណភាពប្រូតេអ៊ីនខ្ពស់របស់ពួកវានៅរដូវវស្សាដែលធ្វើឲ្យត្រីនេះមានរសជាតិឆ្ងាញ់។ ចាប់ពីខែកុម្ភៈដល់មិថុនាពេលដែលពួកវារស់នៅក្នុងទន្លេមេគង្គ និងទន្លេសេកុង ខ្លាញ់ពោះពួកវាបានប្រែជាព៌ណសវិញ អាចប្រហែលមកពីចំណីរបស់វានៅទីនោះ ដែលមិនសម្បូរសារាយប៉េរីហ្វិតុង។

## ៤. ការពិពណ៌នាសង្ខេបអំពីទម្លាប់រស់នៅ បន្តរពូជពង្ស និងវដ្តជីវិតនៃត្រីប៉ាសេអ៊ី

ដោយផ្អែកតាមឯកសារពាក់ពន្ធ័មុនៗ ព្រមជាមួយព៌តមាន និងទន្នន័យដែលបានសិក្សាស្រាវជ្រាវខាងលើ ការពិពណ៌នាសង្ខេបមួយត្រូវបានរៀបរាប់ដូចខាងក្រោមៈ

### ទម្លាប់រស់នៅស៊ីចំណី

ត្រីប៉ាសេអ៊ីជាត្រីដែលរស់នៅជាប្រចាំ នៅក្នុងដែនទឹកខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគីរី និងដែនទឹកនៅភាគខាងត្បូងឈៀងកើតនិងត្បូងបំផុតនៃប្រទេសឡាវ ដែលជាតំបន់ទឹកជ្រូរ មានថ្មរកេតរកូត មានទឹកថ្លាចរន្តទឹកហូរខ្លាំង ស៊ីសារាយប៉េរីហ្វិតុងជាសំខាន់និងស៊ីហ្វីតូប្លង់តុងជាចំណីបន្ទាប់បន្សំ។ ត្រីនេះមានទម្លាប់រស់នៅតែក្នុងតំបន់ដែលមានលក្ខណៈទឹកដូចបញ្ជាក់ខាងលើដែលបានបង្ហាញតាមដំណើរបន្លាស់ទីគេចចេញពីកន្លែងទឹកល្អក់នៃទន្លេមេគង្គ ទន្លេសេកុង និងទន្លេសេសាននៅរដូវវស្សារបស់វា។

### ការធ្វើបន្លាស់ទីដើម្បីស៊ីចំណី និងបន្តរពូជពង្ស

ត្រីប៉ាសេអ៊ីធំធាត់ៗពេញដោយខ្លាញ់ពោះព៌ណបៃតងខ្ចីទាំងធំទាំងតូច បានធ្វើបន្លាស់ទីចេញពីទន្លេស្រែពកនៅពេលទឹកនៅទីនោះចាប់ផ្តើមស្រកនៅដើមរដូវប្រាំង នាខែវិច្ឆិកានៃឆ្នាំ ហើយបន្តរដំណើរតាមទន្លេសេសាន និងទន្លេសេកុងមកប្រមូលផ្តុំ នៅចំណុចប្រសព្វនៃទន្លេសេកុង និងទន្លេមេគង្គដែលមានអន្លង់ធំជ្រៅមួយនៅទីនោះ(ជំរៅ៥០ម)នៅខែធ្នូមុននឹងបំបែកគ្នាទៅរកកន្លែងពងកូន(ចំពោះត្រីធំដែលពេញវ៉ៃយបន្តរពូជ) និងទៅស៊ីចំណី (ចំពោះត្រីដែលមិនទាន់ដល់ពេលបន្តរពូជពង្ស) នៅពេលខ្លាញ់ពោះរលាយជិតអស់នៅដើមខែកុម្ភៈ (នៅពេលនេះត្រីទាំងអស់ស៊ីហ្វីតូប្លង់តុងដែលមាននៅទីនោះជាបន្លែមតិចតួចបំផុត)។ នៅខែកុម្ភៈ-មីនាត្រីពេញវ៉ៃយបន្តរពូជបានធ្វើបន្លាស់ទីទៅសំងំនៅតំបន់ទឹកជ្រូរចំណុចប្រជុំកោះស្នាមជ័យកោះស្រឡៅនិងកោះស្នែង ដើម្បីពងកូន ឯត្រីមិនទាន់បន្តរពូជពង្សបានបែកគ្នាជា២ហ្វូងៈ (១) ហ្វូងត្រីធំៗ ធ្វើបន្លាស់ទីឡើងតាម ទន្លេសេកុងកាត់តាមស្រុកសៀមប៉ាង ហើយបន្តរទៅតំបន់អាតាពើ និងសេកុងប្រទេសឡាវជាចុងក្រោយដើម្បីស៊ីចំណីនៅទីនោះ (២)ហ្វូងត្រីតូចៗ ធ្វើបន្លាស់ឡើងតាមទន្លេមេគង្គទៅតំបន់វឺនខាំ ខាងក្រោមល្បាក់ខោន ប្រទេសឡាវដើម្បីស៊ីចំណីនៅទីនោះ។ ខ្លាញ់ពោះត្រីនៅពេលនេះមានព៌ណសធម្មតា ព្រោះនៅកន្លែងទាំងនោះ មិនមានសម្បូរសារាយប៉េរីហ្វិតុងទេ។ នៅមេសា-ឧសភា ត្រីមេនិងកូនដែលទើបនឹងញាស់នៅសំងំលាក់ខ្លួនស៊ីចំណីនៅកន្លែងដដែល (ត៣) ឯត្រីដែលធ្វើបន្លាស់ទីទៅប្រទេសឡាវទាំង២ហ្វូង បានត្រឡប់មកក្រោមវិញហើយបន្តរចុះទៅស៊ីចំណីនៅចំណុចត្បូងខ្លាខាងត្បូងស្ទឹងត្រែងរួចបន្តរទៅចំណុចខ្សាច់ម្កាក់ខាងជើងខេត្តក្រចេះដើម្បីស៊ីចំណីនៅទីនោះលើកលែងតែត្រីធំៗដែលងាកចូលទៅសំងំស៊ីចំណីនៅតំបន់ទឹកជ្រូរនៃប្រជុំកោះស្នាមជ័យ កោះស្រឡៅ និងកោះស្នែងវិញ។

នាខែមិថុនា នៅពេលដែលទន្លេមេគង្គបានចាប់ផ្តើមជោរជន់ឡើងជាមួយទឹកកករល្អក់នោះ ត្រីប៉ាសេអ៊ីទាំងអស់បាននាំគ្នាចាកចេញពីទន្លេមេគង្គតាមច្រកទន្លេសេកុង និងទន្លេសេសាន មុននឹងធ្វើបន្លាស់ទីចូលទៅទន្លេស្រែពកដែលជំរកដ៏ពិសិទ្ធពេញមួយរដូវវស្សា (ដែលពោរពេញទៅដោយកន្លែងទឹកជ្រូរដែលមានទឹកថ្លា

មានអន្លង់ជ្រៅៗនិងមានចរន្តទឹកហូរខ្លាំងសម្បូរទៅដោយសារាយប៉េរីហ្វីតុង)ដើម្បីស៊ីចំណីនិងបន្តពូជចាប់ពីខែកក្កដាដល់ខែតុលា។

## ៥. ការនេសាទត្រីប៉ាសេអ៊ី សក្តានុពលសេដ្ឋកិច្ច និងការចាប់អារម្មណ៍របស់សង្គម

ការនេសាទត្រីជាពិសេសត្រីប៉ាសេអ៊ីដោយឧបករណ៍មងត្រូវបានសង្កេតឃើញថាមានការកើនឡើងចាប់ពីឆ្នាំ១៩៩៤មក។ ទោះជាមិនមានការកត់ត្រាដោយឡែកអំពីផលនេសាទត្រីប៉ាសេអ៊ីក៏ដោយ ក៏ការប៉ាន់ស្មានដែលអាចជឿទុកចិត្តបានតាមរយៈបរិមាណត្រីចូលទីផ្សាស្ទឹងត្រែង និងទីផ្សាតាមស្រុកភូមិ ត្រីដែលក្រុមហ៊ុនប្រមូលទិញដើម្បីផ្គត់ផ្គង់អ្នកភ្នំពេញនិងនាំចេញអាចបញ្ជាញឲ្យដឹងថាមានប្រហែល២០-៣០តោន/ឆ្នាំចាប់ពីឆ្នាំ១៩៩៤ដល់១៩៩៨ លើកលែងតែឆ្នាំ១៩៩៩ ដែលផលត្រីនេះបានកើនឡើងដល់ប្រហែលជិត៥០តោន ដោយត្រីទំហំតូច(៥០-២០០ក្រ/ក្បាល) ត្រូវចាប់បានយ៉ាងច្រើនរហូតដល់អ្នកមានលទ្ធភាពមួយចំនួនបានទិញយកទៅធ្វើប្រហុក-ផ្អក។ការបណ្តែតបណ្តោយការនេសាទត្រីមានតម្លៃទាំងនៅទំហំតូចៗដូច្នេះគឺជាការបំផ្លិចបំផ្លាញខ្លួនឯងដោយមិនដឹងខ្លួន ព្រោះថាកាលពីនៅឆ្នាំ១៩៩៨ ត្រីប៉ាសេអ៊ីធំជាង១គក្រថ្លៃ៤ម៉ឺនរៀល/គក្រហើយត្រីតូចជាង១គក្រថ្លៃ២-៣ម៉ឺនរៀល/គក្រ។ឯត្រីតូចៗទាំងនោះថ្លៃប្រហែល២-៣ពាន់រៀល/គក្រប៉ុណ្ណោះ ហើយប្រសិនបើទុកឲ្យពួកវា បានរស់នៅធំធាត់តទៅទៀតនោះ ឆ្នាំក្រោយត្រីទាំងនោះនឹងកើនទម្ងន់៣ដង ដូច្នេះអ្នកពាក់ព័ន្ធទាំងអស់ តាំងពីអ្នកនេសាទដល់អ្នកចែកចាយចុងក្រោយនឹងបានទទួលប្រយោជន៍ច្រើនជាងនេះប្រហែល៣០ដងព្រោះត្រីធំថ្លៃជាងត្រីតូច១០ដងហើយត្រូវគុណនឹងទម្ងន់ដែលកើនឡើង៣ដងថែមទៀត។តាមដែលដឹង ផលត្រីប៉ាសេអ៊ីបានធ្លាក់ចុះប្រហែលពាក់កណ្តាលនៅឆ្នាំ២០០០ដែលអាចជាផលប៉ះពាល់ពីការនេសាទត្រីតូចៗនេះផងដែរ។

នៅប៉ុន្មានឆ្នាំចុងក្រោយនេះត្រីប៉ាសេអ៊ីបានឡើងថ្លៃគួរកត់សំគាល់រហូតដល់៣០ម៉ឺនរៀល/គក្រ ចំពោះត្រីធំចាប់ពី១,២គក្រ/ក្បាលឡើងទៅនិង១៥ម៉ឺនរៀល/គក្រចំពោះត្រីដែលតូចជាង១,២ដល់០,៨គក្រ/ក្បាល។នៅ ឆ្នាំ១៩៩៧និង១៩៩៨។ ឆ្នាំ១៩៩៩ ត្រីធំឡើងថ្លៃដល់៤០ម៉ឺន/គក្រ ឯត្រីធំបន្ទាប់ថ្លៃ២០ម៉ឺងរៀល/គក្រ។

ទោះជាការនេសាទត្រីប៉ាសេអ៊ីជាចំណែកដ៏តូចមួយនៃសេដ្ឋកិច្ចជលផល ក៏ដូចជាសេដ្ឋកិច្ចជាតិក៏ដោយ ក៏អត្ថិភាពនៃការនេសាទនេះបានបង្កើតជាមុខរបរមួយឲ្យអ្នកនេសាទខេត្តស្ទឹងត្រែង។ ជាពិសេសទៅទៀត អត្ថិភាពរបស់ត្រីប៉ាសេអ៊ីបានឆ្លុះបញ្ចាំងពីលំនឹងបរិស្ថានធម្មជាតិជាប្រាកដ ដែលជាមោទនភាពនៃការយកចិត្តទុកដាក់ដល់ការអភិរក្សធនធានធម្មជាតិរបស់រាជរដ្ឋាភបាលនិងប្រជាពលរដ្ឋខ្មែរ។

## ៦. ការប្រែប្រួលបរិស្ថាន និងសមត្ថភាពធម្មជាតិក្នុងការសម្របខ្លួនតាមរបស់ត្រីប៉ាសេអ៊ី

ក្នុងអំឡុង២ទសវត្សចុងក្រោយនេះ ផលត្រីប៉ាសេអ៊ីត្រូវបានសង្កេតឃើញថាមានការធ្លាក់ចុះជាបន្តបន្ទាប់ ចាប់ពីមានការសាងសង់ទំនប់វារីអគ្គីសនីយ៉ាលីនិងសេសាន១ នៅភាគខាងលើទន្លេសេសាន ដែលអ្នកវិទ្យាសាស្ត្រជលផលមួយចំនួននៅពេលនោះសង្ស័យថាអាចមានការប៉ះពាល់ដល់ជំរកឬកន្លែងស៊ីចំណីឬកន្លែងពងកូនខ្លះរបស់ត្រីប៉ាសេអ៊ី។ ថ្មីៗនេះផលត្រីប៉ាសេអ៊ីបានធ្លាក់ចុះយ៉ាងគំហុគ ជាពិសេសក្រោយពេលទំនប់វារីអគ្គីសនីសេសាន២ ចាប់ផ្តើមសាងសង់ បិទច្រកផ្លូវត្រីប៉ាសេអ៊ីចូលទៅទន្លេស្រែពកដែលជាជំរកទឹកថ្លា កន្លែងស៊ីចំណី និងជាកន្លែងពងកូននៅរដូវវស្សា។

ត្រីប៉ាសេអ៊ីជាប្រភេទត្រីដែលរើសជំរករស់នៅនិងរើសចំណីបំផុតព្រោះតែការទម្លាប់រស់នៅកន្លែងដែលមានទឹកថ្លាហើយមានចរន្តហូរខ្លាំង សម្បូរសារាយប៉េរីហ្វីតុង។ ជម្រើសជម្រកសម្រាប់រស់នៅខុសប្លែកគេបែបនេះអាចធ្វើឲ្យត្រីនេះជួបវិបត្តិខ្លាំងនៅពេលមានការប្រែប្រួលបរិស្ថានធម្មជាតិព្រោះកន្លែងធម្មជាតិបែបនេះពុំមានពីរឡើយ ដូច្នេះត្រីប៉ាសេអ៊ីត្រូវប្រឈមនឹងការដាច់ពូជក្នុងពេលឆាប់ៗខាងមុខ។ ការអភិវឌ្ឍន៍ភ្ញាស់បង្កាត់អាចមានលទ្ធភាពធ្វើបានតែត្រូវចំណាយពេលវេលាយូរ ហើយចំណាយទុនច្រើន ទើបទទួលបានជោគជ័យ។៕

ដោយ ទូច ស៊ាងតាណា



ពហុកីឡាដ្ឋានជាតិមរតកតេជោ



ឧទ្យានជាតិរមណីយដ្ឋានភ្នំបូកគោនៅខេត្តកំពត